# សង្កេតការណ៍

## ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម

៥

# សវនាការលើអង្គសេចក្តី ករណី ០០២

ខែធ្នូ ឆ្នាំ២០១១



## មាតិកា


**សវនាការលើអង្គសេចក្តីសំណុំរឿង០០២**
សេចក្តីផ្តើម ១
សេចក្តីសន្និដ្ឋានចោទប្រកាន់ ២
ការឆ្លើយតបរបស់ជនជាប់ចោទ ១០
សេចក្តីសន្និដ្ឋាន ២២
បញ្ហាផ្សេងៗ ២២
**សេចក្តីសម្រេចរបស់សាលាដំបូង ស្តីអំពីសម្បទា អៀង ធីរិទ្ធ ២៥**
**បណ្តឹងជិតចិត្តប្រឆាំងទៅនឹងចៅក្រម នៃអង្គជំនុំជម្រះសាលាដំបូង ២៧**



ក្រុមសង្កេតការណ៍ :
គីម ម៉ារីយ៉ាន, ឱ សុជាតា,
លឹម ជ័យទត្ត និង ចាន ប្រាថ្នា


រូបក្របមុខ : លោកស្រី ជា លាង សហព្រះរាជអាជ្ញាជាតិ
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (រូបថត : អ.វ.ត.ក)


មជ្ឈមណ្ឌលឯកសារកម្ពុជា ◆ ស្វែងរកការពិតដើម្បីការចងចាំ និងយុត្តិធម៌ ◆ www.dccam.org



អៀង សារី ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ប្រភព ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ការចាប់ផ្តើមសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង០០២

## ថ្ងៃទី២១-២៣ ខែវិច្ឆិកា ឆ្នាំ២០១១

*ដោយ គីម ម៉ារីយ៉ាន, ឌី សុដាតា, ចាន ប្រាថ្នា និង លឹម ជ័យទត្ត*

## សេចក្តីផ្តើម

នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូង នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបើកសវនាការលើអង្គសេចក្តីនៅក្នុងសំណុំរឿង០០២ ស្តីពីសេចក្តីសន្និដ្ឋានចោទប្រកាន់ដោយសង្ខេបរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងជនជាប់ចោទដែលជាមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហម រួមមាន នួន ជា អៀង សារី និង ខៀវ សំផន ។ ជនជាប់ចោទដែលមានវត្តមាននៅក្នុងសវនាការទាំងបីរូបត្រូវបានចោទពីបទប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ដែលប្រព្រឹត្តនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យរវាងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។

សវនាការលើអង្គសេចក្តីដែលមានរយៈពេលបីថ្ងៃ គឺពីថ្ងៃទី២១ដល់២៣ ខែវិច្ឆកា កន្លងទៅ បានចាប់ផ្តើមឡើងដោយការថ្លែងបើកសេចក្តីសន្និដ្ឋានចោទប្រកាន់សង្ខេបរបស់សហព្រះរាជអាជ្ញាដែលរៀបរាប់ពីបទចោទប្រកាន់ទាំងឡាយប្រឆាំងនឹងជនជាប់ចោទទាំងបីរូបលើអង្គហេតុដែលទាក់ទងនឹង ៖

១) ប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា រួមទាំងតួនាទីរបស់ជនជាប់ចោទម្នាក់ៗ នៅមុនពេលមានការបង្កើតរបបកម្ពុជាប្រជាធិបតេយ្យ ។

២) រចនាសម្ព័ន្ធរបបកម្ពុជាប្រជាធិបតេយ្យ រួមទាំងរចនាសម្ព័ន្ធរដ្ឋបាល ប្រព័ន្ធទំនាក់ទំនង និងរចនាសម្ព័ន្ធយោធា ។

៣) តួនាទីរបស់ជនជាប់ចោទម្នាក់ៗក្នុងជួររដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ការទទួលខុសត្រូវរបស់ជនជាប់ចោទតាមការចាត់តាំងក្របខណ្ឌនៃសិទ្ធិអំណាចរបស់ជនជាប់ចោទ និងខ្សែបណ្តាញទាក់ទងនៅក្នុងរយៈកាលដែលពាក់ព័ន្ធនិងយុត្តាធិការតាមពេលវេលារបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។

៤) គោលនយោបាយនៃរបបកម្ពុជាប្រជាធិបតេយ្យស្តីពីបញ្ហាទាំងឡាយដែលបានលើកឡើងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។

៥) ការចោទប្រកាន់លើអង្គហេតុដែលបានរៀបរាប់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជននៅក្នុងដំណាក់កាលទី១ និងដំណាក់កាលទី២ ។

៦) ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិរួមមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញ (លើកលែងដោយហេតុផលសាសនា) ការជម្លៀសប្រជាជនដោយបង្ខំ និងការបាត់ខ្លួនដោយ បង្ខំ ។

នៅក្នុងការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់សង្ខេបរបស់ខ្លួន សហព្រះរាជអាជ្ញាបានចំណាយពេលមួយថ្ងៃកន្លះ ដើម្បីធ្វើសេចក្តីថ្លែងការណ៍ចោទប្រកាន់ទៅលើជនជាប់ចោទទាំងបីរូប ។

ដើម្បីអនុញ្ញាតឲ្យជនជាប់ចោទ អាចអនុវត្តសិទ្ធិរបស់ខ្លួនប្រកបដោយប្រសិទ្ធិភាព អង្គជំនុំជម្រះបានអនុញ្ញាតឲ្យជនជាប់ចោទនីមួយៗមានពេលកន្លះថ្ងៃដើម្បីឆ្លើយតបទៅនឹងបទចោទប្រកាន់ទាំងឡាយដែលលើកឡើងដោយសហព្រះរាជអាជ្ញា ។ ប៉ុន្តែនៅក្នុងសវនាការនេះ ជនជាប់ចោទ អៀង សារី បានបដិសេធដោយមិនព្រមធ្វើការឆ្លើយទៅនឹងរាល់បទចោទប្រកាន់ទាំងឡាយរបស់សហព្រះរាជអាជ្ញាឡើយ ដោយផ្តល់ហេតុផលនៅក្នុងសេចក្តីប្រកាសរបស់ខ្លួនថា ខ្លួនធ្លាប់ត្រូវបានទទួលការលើកលែងទោស និងអនុគ្រោះទោសដែលផ្តល់ឲ្យដោយអតីតព្រះមហាក្សត្រសម្តេច

ព្រះ នរោត្តម សីហនុ រួចហើយ ។

រីឯសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានអនុញ្ញាតឲ្យធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ ឬឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានណាមួយរបស់ភាគីឡើយ ទោះបីជាសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសំណើដោយផ្ទាល់មាត់នៅក្នុងសវនាការក៏ដោយ ។

### ១) សេចក្តីសន្និដ្ឋានចោទប្រកាន់របស់សហព្រះរាជអាជ្ញា

ក្នុងរយៈពេលមួយថ្ងៃកន្លះ គឺនៅថ្ងៃទី២១និង២២ ខែវិច្ឆិកា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាទាំងពីរបានធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ពាក់ព័ន្ធនឹងអង្គហេតុដែលបានកើតឡើង និងចេតនាប្រព្រឹត្តបទល្មើសរបស់ជនជាប់ចោទនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ សេចក្តីសន្និដ្ឋាននេះត្រូវបានធ្វើជាពីរដំណាក់កាលគឺ ដំណាក់កាលទី១) សហព្រះរាជអាជ្ញាជាតិ លោកស្រី ជា លាង បានលើកឡើងពីអង្គហេតុដែលជាអំពើឧក្រិដ្ឋកម្មដូចជាការជម្លៀសប្រជាជន ការដាក់ឲ្យជាទាសករ ការសម្លាប់រង្គាលប្រជាជនកម្ពុជា និងជនជាតិភាគតិច និងអាពាហ៍ពិពាហ៍ដោយបង្ខំ ។ ដំណាក់កាលទី២) លោក អេនឌ្រូ ខេលី សហព្រះរាជអាជ្ញាអន្តរជាតិធ្វើការបង្ហាញពីតួនាទី និងការទទួលខុសត្រូវរបស់ជនជាប់ចោទទាំងបីរូបចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ។

### ក) សេចក្តីថ្លែងចោទប្រកាន់របស់សហព្រះរាជអាជ្ញាជាតិ

នៅក្នុងសេចក្តីថ្លែងសន្និដ្ឋានចោទប្រកាន់របស់ខ្លួន សហព្រះរាជអាជ្ញាជាតិលោកស្រី ជា លាង បានចាប់ផ្តើមដោយលើកឡើងពីការបាត់បង់ជីវិតរបស់ប្រជាជនកម្ពុជា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយបញ្ជាក់ថា ប្រជាជនប្រមាណ ១,៧លាននាក់ទៅ ២,២លាននាក់ ឬមួយភាគបួននៃប្រជាជនបានស្លាប់បាត់បង់ជីវិតដោយសារអំពើរបស់ជនជាប់ចោទក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយប្រជាជនដែលរស់រានមានជីវិតរហូតមកដល់បច្ចុប្បន្ននេះបានទទួលរងនូវផលប៉ះពាល់ពីអំពើរបស់ជនជាប់ចោទ ។ អំពើទាំងនោះរួមមាន ៖ ការជម្លៀសដោយបង្ខំដែលមានលក្ខណៈជាប្រព័ន្ធ ការធ្វើពលកម្មដោយបង្ខំ លក្ខខណ្ឌជីវិត ការជម្លៀសក្នុងដំណាក់កាលទីពីរ ការលុបបំបាត់ចោលព្រះពុទ្ធសាសនា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ការធ្វើទារុណកម្ម ការកាប់សម្លាប់ អំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិចាម និងវៀតណាម ។

### ១) ការជម្លៀសដោយបង្ខំដែលមានលក្ខណៈជាប្រព័ន្ធ

សហព្រះរាជអាជ្ញាជាតិបានលើកឡើងថា នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខណៈពេលដែលកងទ័ពខ្មែរក្រហមកាន់កាប់ទីក្រុងភ្នំពេញ ការជម្លៀសដ៏គួរឲ្យរន្ធត់មួយបានកើតឡើង ។ ខ្មែរក្រហមបានប្រកាសឲ្យប្រជាជនចេញពីលំនៅឋាន ដោយយកមូលហេតុថាអាមេរិកនឹងមកទម្លាក់គ្រាប់បែកមកលើទីក្រុងភ្នំពេញ ។ ប្រជាជនត្រូវបានបង្ខំឲ្យចេញពីផ្ទះសម្បែង ទ្រព្យសម្បត្តិ ហើយឆ្ពោះទៅកាន់ទីជនបទឆ្ងាយៗដែលបណ្តាលឲ្យបែកបាក់គ្រួសារ ។ លោកស្រីព្រះរាជអាជ្ញា ជា លាង បានបន្ថែមថា អ្នកជំងឺត្រូវបានបង្ខំឲ្យចេញពីមន្ទីរពេទ្យ ស្ត្រីមានផ្ទៃពោះអ្នកដែលទើបនឹងសម្រាលកូនហើយត្រូវពរកូនចាកចេញទៅ ។ ការជម្លៀសបានធ្វើឲ្យមានសភាពកកកុញ ហើយខ្មែរក្រហមបានសម្លាប់អ្នកដែលប៉ុនប៉ងរត់គេច និងអ្នកដែលបានប្រព្រឹត្តកំហុសបន្តិចបន្តួចជាដើម ។ លោកស្រីព្រះរាជអាជ្ញាបានបន្តថា ប្រជាជនជាច្រើនបានស្លាប់បាត់បង់ជីវិតនៅអំឡុងពេលនៃការជម្លៀសដោយសារជំងឺ មិនមានអាហារបរិភោគ និងការរត់ជាន់គ្នាជាដើម ។ មានសាកសពមនុស្សនៅពាសពេញផ្លូវ ហើយកងទ័ពខ្មែរក្រហមបានបើកឡានកិនលើមនុស្ស



សហព្រះរាជអាជ្ញាជាតិ ជា លាង (រូបថត ៖ អ.វ.ត.ក)

និងសាកសពទាំងនោះដូចសត្វធាតុ ។ លោកស្រីសហព្រះរាជអាជ្ញា ជា លាង បានបញ្ជាក់ថា នៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ និងថ្ងៃក្រោយបន្ទាប់មកទៀត ខ្មែរក្រហមបានជម្លៀសប្រជាជនចេញពីគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជា ដោយបានលើកឡើងនូវសម្តីរបស់ជនជាប់ចោទ ខៀវ សំផន ដែលបានឆ្លើយនៅចំពោះមុខចៅក្រមស៊ើបអង្កេតថា «ខ្ញុំដឹងថាចំនួនប្រជាជនអាចនឹងធ្លាក់ចុះតាមផ្លូវ» និងសម្តីរបស់ជនជាប់ចោទ អៀង សារី ដែលបានលើកឡើងថា «មានមនុស្សរាប់ពាន់នាក់ស្លាប់ពេលជម្លៀស និងថា ការចាប់ផ្តើមដំបូងនៃបដិវត្តន៍នេះមានមនុស្សស្លាប់ច្រើន» ។ លោកស្រីបានលើកឡើងថា ការស្វែងរកខ្មាំងត្រូវចាប់ផ្តើមភ្លាមៗ ហើយការកាប់សម្លាប់មុនគេគឺ ទាហានរបស់រដ្ឋាភិបាល លន់ នល់ ទោះបីជាទាហានទាំងនោះបានទម្លាក់អាវុធចុះចូលក៏ដោយ ។ ការចាប់ខ្លួនត្រូវបានធ្វើឡើងក្រោមរូបភាពនៃការបោកបញ្ឆោតថា អ្នកដែលធ្លាប់ធ្វើការនៅក្នុងរបបមុនមានឋានៈអ្វី នឹងផ្តល់ឋានៈនោះឲ្យវិញ ។ ពេលអ្នកដែលធ្លាប់ជាទាហាន ឬមន្ត្រីរាជការព្រមទៅសារភាពអ្នកទាំងនោះនឹងត្រូវបានយកទៅសម្លាប់ចោល ។ លោកស្រីសហព្រះរាជអាជ្ញាជាតិ ជា លាង បានបន្តថា ទីតាំងពិឃាដមួយនៅទួលជ្រៃ(ខាងលិច) ទាហាន និងមន្ត្រីរាជការរាប់ពាន់នាក់ត្រូវបានសម្លាប់ ហើយសាកសពត្រូវបានដាក់ទៅក្នុងរណ្តៅសាកសពរួមដូចជាសម្រាម ។ ក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ មានអ្នកជម្លៀសរាប់ពាន់នាក់ត្រូវបានយកទៅសម្លាប់ចោលនៅវត្តត្បែង និងនៅកន្លែងផ្សេងទៀតដូចជាក្នុងស្រុកកំពង់ត្រឡាច ។ លោកស្រីសហព្រះរាជអាជ្ញាបានសង្កត់ធ្ងន់ថា មានភ័ស្តុតាងជាច្រើនដែលបង្ហាញថា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺជាបញ្ជារបស់មេដឹកនាំបក្សកុម្មុនីស្តកម្ពុជា ។

## ២) ការធ្វើពលកម្មដោយបង្ខំ

លោកស្រីសហព្រះរាជអាជ្ញា ជា លាង បានលើកឡើងថា ការជម្លៀសគ្រាន់តែជាការចាប់ផ្តើមតែប៉ុណ្ណោះ អ្វីដែលធ្វើឲ្យរន្ធត់នោះ គឺការបង្ខំឲ្យធ្វើពលកម្មការកាត់បន្ថយវណ្ណៈមកជាវណ្ណៈកសិករ ។ សង្គមនិងទ្រព្យសម្បត្តិឯកជនត្រូវលុបបំបាត់ និងដកហូត ។ សាលារៀន ទីផ្សារ សៀវភៅ វិទ្យុទូរទស្សន៍ សិល្បៈអក្សរសាស្ត្រ គ្រប់សាសនាទាំងអស់ត្រូវបានបំបិទ និងហាមឃាត់ ។ លោកស្រីបានបន្ថែមថា ប្រជាជនទាំងអស់ត្រូវបានដាក់ឲ្យធ្វើការនៅក្នុងការដ្ឋានចំនួន៥កន្លែងដែលប្រជាជនទាំងនោះត្រូវបានបង្ខំឲ្យធ្វើការដូចដែលបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ ។ ការដ្ឋានទាំងនោះរួមមាន ៖

១) សហករណ៍ត្រាំកក់ ខេត្តតាកែវ

២) សហករណ៍ស្រែអំបិល ខេត្តកំពត

៣) ទំនប់១មករា ខេត្តកំពង់ធំ

៤) ទំនប់ត្រពាំងថ្ម ខេត្តបន្ទាយមានជ័យ

៥) ការដ្ឋានព្រលានយន្តហោះ ខេត្តកំពង់ឆ្នាំង

លោកស្រីសហព្រះរាជអាជ្ញាបានលើកឡើងថា ជនជាប់ចោទបានបញ្ជាតាមខ្សែបណ្តោយយ៉ាងតឹងរឹង ហើយបានរក្សាបញ្ជាលើទីតាំងទាំង៥កន្លែងនេះយ៉ាងតឹងរឹង ។ ចំពោះទំនប់ត្រពាំងថ្ម ជនជាប់ចោទ ខៀវ សំផន បានចុះទៅពិនិត្យជាញឹកញាប់ រីឯទំនប់១មករាវិញ ក៏ធ្លាប់មានមេដឹកនាំខ្មែរក្រហមចុះទៅត្រួតពិនិត្យដែរ ដូចជា ប៉ុល ពត នួន ជា អៀង សារី ខៀវ សំផន និងមានគណៈមជ្ឈិមបក្សផ្សេងទៀត ។ ប្រជាជនត្រូវបានបង្ខំឲ្យធ្វើការជាទម្ងន់ និងមិនទទួលបាននូវការឈប់សម្រាក និងអាហារគ្រប់គ្រាន់ឡើយ ដែលការណ៍នេះធ្វើឲ្យប្រជាជនទាំងអស់នោះឆ្លងនូវជំងឺផ្សេងៗ និងបានស្លាប់បាត់បង់ជីវិតជាច្រើន ។

## ៣) លក្ខខណ្ឌជីវិតរស់នៅ

លោកស្រីសហព្រះរាជអាជ្ញាជាតិ ជា លាង បានលើកឡើងថា ស្ថានភាពរស់នៅរបស់ប្រជាជនកម្ពុជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានសភាពដូចជាទាសករ ។ ដោយលោកស្រីបានបន្តថា អាយុជីវិតរបស់ប្រជាជនត្រូវបានគេគ្រប់គ្រងទាំងស្រុង ហើយប្រទេសកម្ពុជាទាំងមូលក្លាយជាគុកឥតជញ្ជាំង ។ ការកំណត់លក្ខខណ្ឌការងារសម្រាប់ប្រជាជនមើលទៅហាក់បីដូចជាគួរឲ្យរន្ធត់ ដោយលោកស្រីសហព្រះរាជអាជ្ញាបានលើកឡើងពីស្ត្រីរងគ្រោះម្នាក់ដែលត្រូវបានបង្ខំឲ្យធ្វើការនៅសហករណ៍ស្រែអំបិលរហូតដល់ទឹកស៊ីជើងអស់ ហើយស្ត្រីជាច្រើនទៀតត្រូវបានប្រើឲ្យអូសរទេះអំបិលធ្ងន់ៗ និងសម្តីរបស់ជនជាប់ចោទ ខៀវ សំផន ដែលបានលើកឡើងនៅក្នុងពិធីអបអរសាទបក្សកុម្មុយនីស្តកម្ពុជាក្នុងរបបនោះថា «គ្មានម៉ាស៊ីន អ្វីទាំងអស់ការធ្វើគឺពឹងលើកម្លាំងប្រជាជន

ទាំងស្រុង» ។ ក្រៅពីនោះ ការធ្វើការត្រូវធ្វើទៅតាមចំនួនកំណត់ប្រជាជនរាប់ពាន់នាក់ត្រូវស្នាក់នៅ និងហូបចុករួមគ្នា ។ រីឯរបបអាហារមិនមានគ្រប់គ្រាន់ ការបង្ខំឲ្យធ្វើការ និងហាមឃាត់មិនឲ្យស្វែងរកអាហារ ហើយដាក់ទណ្ឌកម្មចំពោះអ្នកណាដែលស្វែងរកអាហារបន្ថែម ។ លោកស្រីព្រះរាជអាជ្ញាបានបន្តថា ស្ថានភាពអនាម័យរបស់ប្រជាជនគឺស្ថិតនៅក្នុងសភាពយ៉ាប់យ៉ឺន ដោយមិនមានបង្គន់អនាម័យសម្រាប់បន្ទោរបង់ រួយមាននៅស្ទើរគ្រប់ទីកន្លែង រីឯអ្នកជំងឺត្រូវបានចោទប្រកាន់ថាធ្វើពុត ហើយការព្យាបាលត្រូវបានធ្វើឡើងដោយពេទ្យដែលមិនមានជំនាញ និងមិនមានចំណេះដឹង ដូចជាការឲ្យថ្នាំអាចម៍ទន្សាយ និងចាក់ទឹកដូងជាដើម ។ ប្រជាជនត្រូវបានបង្ខំឲ្យធ្វើប្រវត្តិរូបដើម្បីបក្សកុម្មុយនីស្តតាមរកអ្នកក្បត់បដិវត្ត ។ លោកស្រីបានបញ្ជាក់បន្ថែមថា មនុស្សគ្រប់រូបត្រូវបានដាក់ឲ្យស្ថិតក្នុងការប្រជុំតិតៀន និងការស្វ័យតិតៀន ។ ការដ្ឋាននីមួយៗមានការដាក់ទណ្ឌកម្ម ទៅលើប្រជាជនដែលឈឺច្រើន គ្មានកំលាំងធ្វើការងារ ប្រជាជនដែលដើរស្វែងរកអាហារ និងការធ្វើការងារមិនបានតាមផែនការ ។ ចំពោះការលួចចំណីអាហារវិញ បើចាប់បាននឹងត្រូវគេយកទៅសម្លាប់ចោល ។ សហព្រះរាជអាជ្ញាបានលើកឡើងពីភាពស៊ីសង្វាក់គ្នាចំពោះវិធីសាស្ត្រដែលត្រូវបានយកមកប្រើនៅក្នុងការរដ្ឋានទាំង៥កន្លែង ដោយលើកឡើងពីសាក្សីម្នាក់ដែលបានឃើញអ្នកទោសមួយរូបត្រូវបានបង្គាប់ឲ្យជីករណ្តៅ ហើយត្រូវបានគេយកចបវាយទម្លាក់ចូលរណ្តៅដែលខ្លួនបានជីកនោះ ។ រីឯស្ត្រីដែលមានផ្ទៃពោះត្រូវបានវាយទម្លាក់ចូលទំនប់ត្រពាំងថ្មដើម្បីធ្វើឲ្យទំនប់ជាប់ល្អ ហើយនៅតាមការដ្ឋានជាច្រើន ពលករបានធ្វើអត្តឃាតព្រោះតែមិនអាចទ្រាំបាន ។

## ៤) ការជម្លៀសក្នុងដំណាក់កាលទីពីរ

លោកស្រីសហព្រះរាជអាជ្ញាជាតិ ជា លាង បានបញ្ជាក់នៅក្នុងសេចក្តីសន្និដ្ឋានចោទប្រកាន់របស់ខ្លួនថា ការជម្លៀសប្រជាជនត្រូវបានធ្វើឡើងក្នុងទ្រង់ទ្រាយធំ ប្រជាជនត្រូវបានជម្លៀសសាជាថ្មីដើម្បីសម្រេចគោលនយោបាយ ខែសីហា ក្នុងឆ្នាំ១៩៧៥ ដើម្បីបង្កបង្កើនផលិតផលស្រូវនៅក្នុងភូមិភាគពាយ័ព្យ ។ នៅក្នុងគោលនយោបាយនោះ ក្រុមខ្មែរក្រហមបាននាំកម្លាំងបន្ថែមទៀតដើម្បីបង្កើនកម្លាំងផលិត ។ នៅក្នុងការជម្លៀសលើកទីពីរនេះត្រូវបានលោកស្រីសហព្រះរាជអាជ្ញាបញ្ជាក់ថា ប្រជាជនត្រូវបានជម្លៀសដោយដឹកតាមគ្រប់មធ្យោបាយទៅកាន់ខេត្តពោធិ៍សាត់ ដោយប្រជាជនជាច្រើនបានស្លាប់ដោយសារការអត់អាហារ ការជាន់គ្នាស្លាប់ និងភាពគ្មានអនាម័យ ។ លោកស្រីបានបន្តថា តំបន់ដែលជម្លៀសប្រជាជនទៅនេះមិនមានអាហារបម្រុងនោះទេ ដោយសារមជ្ឈិមបក្សមិនបានបញ្ជូនស្រូវអង្ករទៅឲ្យភូមិភាគពាយ័ព្យ ។ មនុស្សស្លាប់ប្រមាណ១០នាក់ក្នុង១ថ្ងៃ ដោយការអត់អាហារ ។ លោកស្រីសហព្រះរាជអាជ្ញាបានបញ្ជាក់ថា ក្រុមមេដឹកនាំនៅមជ្ឈិមបក្សបានដឹងពីការកាប់សម្លាប់ដ៏សាហាវ ដែលបានកើតឡើងនៅភូមិភាគពាយ័ព្យ ។

## ៥) ការលុបបំបាត់ចោលព្រះពុទ្ធសាសនា

ទាក់ទងនឹងការលុបបំបាត់ចោលព្រះពុទ្ធសាសនា លោកស្រីសហព្រះរាជអាជ្ញាជាតិ ជា លាង បានអះអាងថា ការលុបបំបាត់ចោលព្រះពុទ្ធសាសនាត្រូវបានចាប់ផ្តើមដោយខ្មែរក្រហម ដោយសារគេយល់ឃើញថា សាសនាព្រះពុទ្ធជាស្ថាប័នកេងប្រវ័ញ្ច ។ ព្រះសង្ឃត្រូវបានចាត់ទុកជាពួកសក្តិភូមិ ជញ្ជក់ឈាមប្រជាជន ដោយត្រូវបានទទួលរងការធ្វើទុក្ខបុកម្នេញតាមរយៈបញ្ជាដាក់លាក់របស់ថ្នាក់លើ ។ ខ្មែរក្រហមបានប្រែក្លាយវត្តអារាមឲ្យក្លាយទៅជាសហករណ៍ មន្ទីរសន្តិសុខ និងកន្លែងសម្លាប់ ។ ព្រះសង្ឃត្រូវបានបង្ខំឲ្យសឹក ក្នុងករណីរឹងរូសនឹងត្រូវសម្លាប់ចោល ។ លោកស្រីសហព្រះរាជអាជ្ញាបានបញ្ជាក់ថា ការធ្វើទុក្ខបុកម្នេញលើព្រះពុទ្ធសាសនាពីសំណាក់ក្រុមខ្មែរក្រហមគឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។

## ៦) ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ

ទាក់ទីងនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ លោកស្រីសហព្រះរាជអាជ្ញាជាតិ ជា លាង បានបញ្ជាក់ ថា ខ្មែរក្រហមបានលុបបំបាត់ចោលនូវវប្បធម៌ទាំងអស់ ហើយគោលនយោបាយនេះបានស្តែងឡើងតាមរយៈការរំលោភសេពសន្ថវៈដែលកើតឡើងជាទ្រង់ទ្រាយធំ ហើយប្រជាជនរងគ្រោះដោយសារការបង្ខំឲ្យរៀបការ ។ លោកស្រីបានបន្តថាអាពាហ៍ពិពាហ៍ដោយបង្ខំកើតឡើងដោយប្រឆាំងនឹងសង្គម និងជីវិតគ្រួសារ ហើយការរៀប

អាពាហ៍ពិពាហ៍ដោយស្ម័គ្រចិត្ត និងតាមប្រពៃណីត្រូវបានលុបបំបាត់ចោល ។ លោកស្រីបានសង្កត់ធ្ងន់ថា ខ្មែរក្រហមបានចាប់ឲ្យប្រជាជនរៀបការម្តង១១៧គូ ដោយការបិទភ្លើងហើយចាប់ដៃគ្នា ហើយកម្មាភិបាលខ្មែរក្រហមបានដាក់ឲ្យមានការត្រួតពិនិត្យឲ្យមានការរួមភេទ ដោយឲ្យពួកឈ្លបលបស្តាប់នៅខាងក្រោមផ្ទះរបស់ប្រជាជន ។ ជនរងគ្រោះមិនព្រមរួមដំណេករយៈពេលបីយប់នឹងត្រូវបានខ្មែរក្រហមយកទៅសម្លាប់ចោល ។ លោកស្រីព្រះរាជអាជ្ញាបានលើកពីជនរងគ្រោះម្នាក់ដែលត្រូវបានបង្ខំឲ្យរួមដំណេកជាមួយប្តីថ្មីរបស់គាត់ ដោយគាត់មិនព្រម ប្តីថ្មីរបស់គាត់បានរាយការណ៍ទៅអង្គការ បន្ទាប់មកគាត់ត្រូវបានគេបង្ខំឲ្យដោះសម្លៀកបំពាក់ឲ្យបុរសនោះរំលោភ ។ សហព្រះរាជអាជ្ញាជាតិបានលើកឡើងថា គោលនយោបាយអាពាហ៍ពិពាហ៍ដោយបង្ខំមានបញ្ជាក់នៅក្នុងសៀវភៅ ក្រហមរបស់ ប៉ុល ពត ដែលបញ្ជាក់ថា ដៃគូដែលស្រលាញ់គ្នាខ្លាំងមិនអនុញ្ញាតឲ្យរៀបអាពាហ៍ពិពាហ៍នោះទេ ។

## ៧) មន្ទីរសន្តិសុខ ការធ្វើទារុណកម្ម និងការកាប់សម្លាប់

ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ លោកស្រីសហព្រះរាជអាជ្ញាជាតិបានបញ្ជាក់ថា មន្ទីរសន្តិសុខទាំងអស់គឺត្រូវបានប្រើដើម្បីឃុំខ្លួន និងកម្ទេចខ្មាំង ។ ខ្មែរក្រហមបានចាប់ខ្លួន សួរចម្លើយ និងសម្លាប់អ្នកទោសណាដែលខ្លួនចាត់ទុកថាជាខ្មាំង ។ បន្ទាប់ពីឆ្នាំ១៩៧៦ ខ្មែរក្រហមចាប់ផ្តើមដាក់ខ្មាំងប្រភេទថ្មី ហើយបានធ្វើចលនាបោសសំអាតផ្ទៃក្នុងរបស់ពួក សេ អ៊ី អា *(CIA)* និងពួក កា ហ្សេ បេ (KGB) នៅក្នុងសម័យនោះដូចមាននៅក្នុងឯកសាររបស់លោក ដេវីដឆេនដល័រ ដែលមានចំណងជើងថា នៅក្រោយជញ្ជាំងស-២១ ។ ការស្វែងរកចាប់ និងសម្លាប់ខ្មាំងត្រូវបានធ្វើនៅពេលមានការសង្ស័យ ។ មន្ទីរសន្តិសុខធំជាងគេគឺ ស-២១ និងមន្ទីរសន្តិសុខខត្តរ(ដែលមានដាកអ្នកទោសប្រមាណ ៥០០នាក់) ។ លោកស្រីព្រះរាជអាជ្ញា បានលើកឡើងទៀតថា បក្សកុម្មុយនីស្ត និងជនជាប់ចោទបានទទួលរបាយការណ៍កម្ចាត់ខ្មាំងជាទៀងទាត់ និងមានការបញ្ជូនចម្លើយសារភាពពីស-២១ ទៅកងពល១០៥ ដើម្បីចាប់អ្នកដែលមានឈ្មោះនៅក្នុងបញ្ជីចម្លើយសារភាព ។ នៅក្នុងមន្ទីរសន្តិសុខអ្នកទោសខ្លះត្រូវបានឃុំខ្លួនទាំងអាក្រាត រស់នៅក្នុងមន្ទីរឃុំខ្លួនលាយឡំគ្នា បរិភោគនិងបន្ទោរបង់នៅជាមួយគ្នា ។ អ្នកទោសពេលខ្លះត្រូវបរិភោគអាហារដាក់ក្នុងម្ជូក ឬកេះគ្រាប់កាំភ្លើងដែលខ្លួនបានបន្ទោរបង់ដាក់នោះ ។ អ្នកទោសត្រូវធ្វើពលកម្មដោយបង្ខំតាំងពីម៉ោង៣យប់ដល់កណ្តាលអាធ្រាត្រ ។ អ្នកទោសមួយចំនួនត្រូវបានគេបូមឈាមចេញពីខ្លួនរហូតដល់ស្លាប់ ។ ប្រភេទនៃការដាក់ទណ្ឌកម្មនៅមន្ទីរសន្តិសុខរួមមានដូចជា ៖

- ការវាយនឹងដែកក្រៀវទេះ ។
- ការធ្វើទារុណកម្ម ។
- ការសម្លាប់និងកប់ទាំងរស់ ។
- ចំពោះអ្នកទោសដែលចង់រត់គេច នឹងត្រូវយកមកដំដែកគោលជាប់នឹងជើង ។
- ទម្រង់ទូទៅមានការវាយ ឆក់ខ្សែរភ្លើង និងការធ្វើឲ្យថប់ដង្ហើម ។

ការសួរចម្លើយធ្វើឡើងជារៀងរាល់ថ្ងៃ ហើយបើសួរមិនឆ្លើយត្រូវបន្តសួររហូតដល់ស្លាប់ ។ ខ្មែរក្រហមបានប្រើវិធីគ្រប់បែបយ៉ាងក្នុងការធ្វើទារុណកម្ម ហើយវិធីធ្វើទារុណកម្មទាំងនោះមានលក្ខណៈសាហាវឃោរឃៅ ។ អ្នកទោសមួយចំនួនបានធ្វើអត្តឃាតដោយមិនអាចទ្រាំបាននឹងការធ្វើទារុណកម្ម ។ ការសម្លាប់អ្នកទោសត្រូវបានធ្វើឡើងតាមវិធីជាក់លាក់ដូចជា ៖

- ធ្វើឡើងពេលយប់ដោយសម្ងាត់ ។
- របៀបសម្លាប់មានលក្ខណៈស្ទើរតែដូចគ្នាគឺ អារក វាយក្បាល ឬកញ្ចឹងកនឹងដែកក្រៀវទេះ ។
- ការសម្លាប់សូម្បីក្មេងត្រូវសម្លាប់យ៉ាងសាហាវឃោរឃៅដូចជាបោកទៅនឹងគល់ឈើ ។
- ការសម្លាប់នៅមន្ទីរសន្តិសុខទាំងនេះមានរាប់ម៉ឺននាក់ ។

លោកស្រីព្រះរាជអាជ្ញាបានលើកឡើងថា មេដឹកនាំរបស់បក្សកុម្មុយនីស្តបានដឹងច្បាស់ពីអំពើឧក្រិដ្ឋកម្មដែលកើតឡើងតាមរយៈទស្សនាវដ្តីទង់បដិវត្ត ការរាយការណ៍តាមសារទូរលេខ សេចក្តីថ្លែងការណ៍របស់ជនជាប់ចោទផ្ទាល់ ។

## ៨) អំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិចាម

ចំពោះអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិចាម លោកស្រីសហព្រះរាជអាជ្ញា ជា លាង បានថ្លែងថា បក្សកុម្មុយនីស្ត

កម្ពុជាបានឃោសនាថា គ្មានការរើសអើងសាសនា ។ ប៉ុន្តែ ប៉ុល ពត និង នួន ជា បានបង្គាប់ទៅកាន់តំបន់ភូមិភាគឲ្យលុបបំបាត់សាសនា ។ ជនជាតិចាមត្រូវទទួលការបង្ខំឲ្យហូបសាច់ជ្រូក មិនឲ្យប្រណិប័តន៍សាសនាជាដើម ។ ចាប់តាំងពីខែមេសា ឆ្នាំ១៩៧៥ ជនជាតិចាម បានទទួលការធ្វើទុក្ខបុកម្នេញជាប្រព័ន្ធដែលមានដូចជា ៖

- ការហាមឃាត់ការគោរពប្រតិបត្តិសាសនាអ៊ីស្លាម
- ការហាមឃាត់មិនឲ្យប្រើប្រាស់ភាសាអ៊ីស្លាម
- ការបិទព្រះវិហារ និងការប្រែក្លាយព្រះវិហារទៅតាមការប្រើប្រាស់ផ្សេងទៀត
- ការដុតគម្ពីរសាសនា
- ការសម្លាប់មេដឹកនាំជនជាតិចាម និងជនទាំងឡាយណាដែលមិនព្រមបោះបង់ជនជាតិចាម
- ស្ត្រីជនជាតិចាមត្រូវបានហាមមិនឲ្យពាក់កន្សែងតាមសាសនាប្រពៃណីរបស់ខ្លួន
- ហាមមិនឲ្យនិយាយភាសាចាម ហើយជាលទ្ធផលនៅឆ្នាំ១៩៧៩ កុមារជនជាតិចាមមួយចំនួនធំលែងចេះនិយាយភាសាចាម ។

លោកស្រីសហព្រះរាជអាជ្ញាបានបន្តថា ក្នុងចំណោមខ្មាំងរបស់ខ្លួនបក្សកុម្មុយនីស្តកម្ពុជាចាត់ទុកជនជាតិចាមក្នុងប្រភេទពិសេសមួយគឺគេចាត់ទុកជនជាតិចាមជាប្រជាជនទាបជាងប្រជាជន១៧មេសា ។ បក្សកុម្មុយនីស្តកម្ពុជាបានផ្លាស់ប្ដូរកន្លែងជនជាតិចាមទៅរស់នៅលាយឡំគ្នាជាមួយជនជាតិខ្មែរ ។ ជនជាតិចាមត្រូវបានសម្លាប់ដាក់ចូលរណ្ដៅ ហើយមានខ្លះត្រូវបានរំលោភមុនទើបសម្លាប់ក្រោយ ។ មានជនជាតិចាមជាច្រើនបានធ្វើការបះបោរ តែត្រូវបានបក្សកុម្មុយនីស្តកម្ពុជាបង្ក្រាបយ៉ាងឃោរឃៅ ។ ប្រជាជនចាមត្រូវបានចាប់ខ្លួននិងសម្លាប់ចោល ក្រោយពេលគេសួរដឹងថាជាជនជាតិចាម ដោយមិនចាំបាច់សួរថាបានប្រព្រឹត្តកំហុសឡើយ ។ លោកស្រីសហព្រះរាជអាជ្ញាជាតិបានលើកឡើងថា ឧក្រិដ្ឋកម្មដែលបានកើតឡើងនេះជាការប៉ុនប៉ងបំបែក និងសម្លាប់ជនជាតិចាមទាំងនោះ ហើយសហព្រះរាជអាជ្ញា នឹងធ្វើការដាក់ភ័ស្តុតាងឲ្យហួសពីវិមតិសង្ស័យដែលបញ្ជាក់បានថាជាការទទួលខុសត្រូវរបស់ជនជាប់ចោទទាំងនេះ ។

### ៩) អំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិវៀតណាម

លោកស្រីសហព្រះរាជអាជ្ញាជាតិបានបញ្ជាក់ថា ជនជាតិវៀតណាមចំនួនពី១៥ម៉ឺននាក់ទៅ២០ម៉ឺននាក់ ត្រូវបានជម្លៀសចេញពីប្រទេសកម្ពុជានៅឆ្នាំ១៩៧៥ ហើយភាគច្រើនអ្នកទាំងនោះត្រូវបាននិរទេសទៅវៀតណាម ។ ចលនានៃការធ្វើឲ្យពួកគេវិនាសសាបសូន្យបានចាប់ផ្ដើមនៅឆ្នាំ១៩៧៧ ហើយយុទ្ធនាការនេះបានចាប់ផ្ដើមជាប្រព័ន្ធ ។ លោកស្រីបានបន្តថាបក្សកុម្មុយនីស្ដកម្ពុជា បានចាប់ផ្ដើមដឹកនាំប្រជាជនឲ្យស្អប់ជនជាតិវៀតណាម ។ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាចាប់ផ្ដើមចូលរួមក្នុងសកម្មភាពស្អប់ជនជាតិវៀតណាម ។ មិនត្រឹមតែជនជាតិវៀតណាមទេ សូម្បីតែជនជាតិខ្មែរក្រោមក៏ត្រូវទទួលរងគ្រោះដងដែរ ។ នៅក្នុងអំឡុងឆ្នាំ១៩៧៧ ការសម្លាប់កាន់តែមានសភាពធ្ងន់ធ្ងរ គ្រួសារដែលមានសមាជិកដែលមានពាក់ព័ន្ធនឹងជនជាតិវៀតណាម ដូចជាម្ដាយជាជនជាតិវៀតណាម ឪពុកជាជនជាតិខ្មែរ នោះម្ដាយនិងកូនត្រូវតែសម្លាប់ចោល ។ ផ្ទុយទៅវិញ ប្រសិនបើម្ដាយជាជនជាតិខ្មែរ ហើយឪពុកជាជនជាតិវៀតណាមវិញ នោះគេនឹងសម្លាប់ឪពុកដែលជាជនជាតិវៀតណាមនោះចោល ។ លោកស្រីសហព្រះរាជអាជ្ញាបានអះអាងថានៅក្នុងអំឡុងពេលដែលមានជម្លោះប្រដាប់អាវុធរវាងប្រទេសកម្ពុជានិងប្រទេសវៀតណាម ទាហានវៀតណាមត្រូវបានចាប់បញ្ជូនទៅកាន់មន្ទីរស-២១ ហើយការចាប់ខ្លួនជនជាតិវៀតណាមត្រូវបានបញ្ជូនព័ត៌មានទៅកាន់អ្នកដឹកនាំទាំងនោះតាមរយៈអង្គភាព១១៨ ។ ជនជាតិវៀតណាមត្រូវបានសម្លាប់ទាំងអស់ ការសន្និដ្ឋាននេះធ្វើឡើងតាមរយៈសម្ដីរបស់ថ្នាក់ដឹកនាំបក្សដែលនិយាយថា «រហូតមកដល់ពេលនេះ មិនមានជនជាតិវៀតណាមណាម្នាក់រស់នៅក្នុងទឹកដីកម្ពុជាឡើយ» ។ លោកស្រីសហព្រះរាជអាជ្ញាជាតិបានបន្ថែមថា ក្នុងឋានៈជាមេដឹកនាំជនជាប់ចោទមិនបានចាត់វិធានការរារាំង និងផ្ដន្ទាទោសចារីនោះទេ ។ ការកាប់សម្លាប់រង្គាលនៅតែកើតមានបន្តទៀតនៅពេលដែលមានការមិនទុកចិត្តគ្នាកើតឡើង ។ ប្រជាជនដែលត្រូវបានជម្លៀសពីបូព៌ាទៅពាយ័ព្យ (ពីស្វាយរៀងទៅពោធិ៍សាត់) គឺទទួលរងនូវការកាប់សម្លាប់ច្រើនជាងគេ ដោយសារតែពួកគេរស់នៅជិតព្រំប្រទល់

ប្រទេសវៀតណាម ។ ហើយប្រជាជនជាច្រើនត្រូវបានចោទប្រកាន់ថាមិនស្មោះត្រង់ ដោយត្រូវបានក្រុមមេដឹកនាំខ្មែរក្រហមហៅថា ក្បាលយួនខ្លួនខ្មែរ ។

ក្រោយពីបានផ្តល់សំអាងហេតុដូចបានរាប់រៀបខាងលើ លោកស្រីព្រះរាជអាជ្ញាបានសន្និដ្ឋានថា ជនជាប់ម្នាក់ៗត្រូវបានចោទប្រកាន់ដាច់ដោយឡែកពីគ្នា ដោយចោទប្រកាន់ពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ តាមរយៈការចូលរួមយ៉ាងសកម្មក្នុងការដាក់នូវគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាឲ្យអនុវត្តរៀបចំផែនការ បញ្ជា ញុះញង់ដែលនាំឲ្យកើតមាននូវអំពើឧក្រិដ្ឋកម្ម ។

### ១) សេចក្តីថ្លែងចោទប្រកាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ


សហព្រះរាជអាជ្ញាអន្តរជាតិ អេនឌ្រូ ខេលី (ប្រភព ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្រោយពីលោកស្រីសហព្រះរាជអាជ្ញាជាតិ ជា លាង ធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ដោយផ្តោតទៅលើអង្គហេតុដែលជាអំពើឧក្រិដ្ឋកម្ម សហព្រះរាជអាជ្ញាអន្តរជាតិ អេនឌ្រូ ខេលី បានធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់បន្ថែមពាក់ព័ន្ធនឹងរចនាសម្ព័ន្ធរបស់បក្សកុម្មុយនីស្តកម្ពុជា អង្គការចាត់តាំង តួនាទីរបស់ជនជាប់ចោទម្នាក់ៗ ការទទួលខុសត្រូវរបស់ជនជាប់ចោទតាមការចាត់តាំង ក្របខណ្ឌនៃសិទ្ធិអំណាចរបស់ជនជាប់ចោទ និងខ្សែបណ្តាញទាក់ទងនៅក្នុងរយៈកាលដែលពាក់ព័ន្ធ ។ នៅក្នុងសេចក្តីសន្និដ្ឋានចោទប្រកាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ ភាគច្រើនផ្តោតទៅលើចេតនារបស់ជនជាប់ចោទដែលនាំឲ្យកើតមានឧក្រិដ្ឋកម្ម ។

### ១) រចនាសម្ព័ន្ធរបបកម្ពុជាប្រជាធិបតេយ្យ

លោកព្រះរាជអាជ្ញាអន្តរជាតិ ខេលី បានលើកឡើងអំពីរចនាសម្ព័ន្ធរបស់បក្សកុម្មុយនីស្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ថាអ្នកមានអំណាចដឹកនាំលើអង្គភាពភូមិភាគ អង្គភាពយោធា និងក្រសួងនានាដែលត្រូវរាយការណ៍ទៅគណៈមជ្ឈិម ។ ការគ្រប់គ្រងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានបែងចែកចេញជា៧ភូមិភាគ និង២តំបន់ស្វយ័ត (តំបន់១០៥និង៥០៥) ។ អង្គភាពទាំងនោះបានរៀបចំជាអង្គការចាត់តាំងនិងរាយការណ៍ទៅអង្គភាពថ្នាក់លើ ។ នៅក្នុងអង្គភាពនីមួយៗមានលេខាមួយរូប និងសមាជិក ។ ភូមិភាគនីមួយៗយ៉ាងហោចណាស់មានសមាជិក១ឬ២រូបនៅគណៈមជ្ឈិម និងត្រូវទទួលការអប់រំនយោបាយរយៈពេល១ខែដែលឧទ្ទេសនាមដោយជនជាប់ចោទ នួន ជា ។ សហព្រះរាជអាជ្ញាអន្តរជាតិបានបន្តទៀតថា លក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជាតម្រូវឲ្យអង្គភាពភូមិភាគរាយការណ៍ជូនថ្នាក់លើ គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ឲ្យបានដឹងពីការអនុវត្ត ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គណៈអចិន្ត្រៃយ៍បង្កើតគោលនយោបាយប្រចាំសប្តាហ៍នៅមន្ទីរ៨៧០ ។ មន្ទីរនៅតំបន់១០៥ តែងតែបញ្ជូនសារទូរលេខពីតំបន់ទៅកាន់ នួន ជា ហើយតែងតែបានទទួលការឆ្លើយតបពី ប៉ុល ពត និងនួន ជា ។ របាយការណ៍ប្រចាំថ្ងៃដែលត្រូវបញ្ជូនទៅមានដូចជា របាយការណ៍ពីព្រំដែនយួន និងសត្រូវផ្ទៃក្នុងកម្មាភិបាល ប្រជាជនថ្មី និងប្រជាជនមូលដ្ឋាន ។

### ២) អង្គការចាត់តាំង និងបណ្តាញទំនាក់ទំនង

ទាក់ទងនឹងអង្គការចាត់តាំង និងបណ្តាញទំនាក់ទំនង លោកព្រះរាជអាជ្ញាអន្តរជាតិ ខេលី បានលើកឡើងពីការទាក់ទងរវាងប្រធានភូមិភាគនានាជាមួយនឹងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដូចជា ខៀវ សំផន អៀង សារី និង នួន ជា ។ លោកព្រះរាជអាជ្ញាបានអះអាងថា ពួកគេបានទាក់ទងជាញឹកញាប់ជាមួយនឹងមេដឹកនាំទាំងអស់នេះ និងបានរាយការណ៍រាល់ព័ត៌មានទាំងឡាយនៅក្នុង

ភូមិភាគរបស់ខ្លួន ។ មកដល់ពេលនីមួយៗចូលរួមយ៉ាងសកម្មទាក់ទង ទៅ សុន សេន ដែលការណ៍នេះបានបញ្ជាក់យ៉ាងច្បាស់ពីគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យដែលត្រូវអនុវត្តរបៀបណាទៅកងពលយោធាក្នុងការបោសសម្អាតខ្មាំង ដែលព័ត៌មាននេះត្រូវបានរាយការណ៍បន្តពី សុន សេន ទៅថ្នាក់លើ (ការរាយការណ៍នៅក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ឬ ប៉ុល ពត) ។ មានសារទូរលេខខ្លះផ្ញើជូនទៅគណៈអចិន្ត្រៃយ៍ដើម្បីរាយការណ៍ពីចំនួនទឹកភ្លៀង និងការត្អូញត្អែររបស់សហករណ៍ ។ ព្រះរាជអាជ្ញាបានលើកឡើងថា ឧក្រិដ្ឋកម្មដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យមិនមែនជារឿងចៃដន្យទេ គឺជាឧក្រិដ្ឋកម្មកើតចេញពីគោលនយោបាយរបស់អ្នកដឹកនាំ ដែលមានការចូលរួមពីមនុស្សជាច្រើន និងបានប្រហារជីវិតមនុស្សរាប់លាននាក់ ។ ហើយជនជាប់ចោទមានហេតុផលគ្រប់គ្រាន់ដែលអាចដឹងឧក្រិដ្ឋកម្មដែលបានកើតឡើងតាមរយៈការចាត់តាំង និងបណ្តាញទំនាក់ទំនងនេះ ។

### ៣) ការជម្លៀសប្រជាជនដោយបង្ខំ

លោកព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងពីការជម្លៀសដោយបង្ខំ ដែលជាឧក្រិដ្ឋកម្មមួយកើតឡើងក្រោមការទទួលខុសត្រូវរបស់ជនជាប់ចោទ ។ ខ្មែរក្រហមបានបង្ខំឲ្យប្រជាជនចាកចេញពីផ្ទះរបស់ពួកគេ វត្តអារាមត្រូវបានបិទ មិនថាមនុស្សនោះជាអ្នកណា គ្រូពេទ្យ ព្រះសង្ឃ ជីវិតរបស់អ្នកទាំងនោះគឺជារបស់បក្សទាំងអស់ ។ គោលនយោបាយនេះជាផែនការណ៍ដែលធ្វើឡើងដោយប្រុងប្រយ័ត្នដោយជនជាប់ចោទទាំងនេះ ។ សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា ខៀវ សំផន បានដឹកនាំសកម្មភាពនេះ ហើយសកម្មភាពនោះស្តែងឡើងតាមរយៈសុន្ទរកថារបស់ជនជាប់ចោទ ខៀវ សំផន នៅប្រទេសកូរ៉េខាងជើង ។ អៀង សារី និង អៀង ធីរិទ្ធបានប្រកាសពីការកម្ទេចខ្មាំងបាន៥ម៉ឺននាក់ ។ អៀង សារី ដែលជាសមាជិកភាពក្នុងបក្សកុម្មុនីសកម្ពុជានៅទីក្រុងប៉េកាំងបានរៀបចំផែនការជម្លៀសប្រជាជននៅឆ្នាំ១៩៧៤ ជាមួយ ប៉ុល ពត ។ ការជម្លៀសមិនមែនដើម្បីការពារប្រជាជនឬផ្គត់ផ្គង់ស្បៀងអាហារនោះទេ ។ ការជម្លៀសនេះជាគំនិតដែលកើតចេញពីបក្សកុម្មុយនីស្តកម្ពុជាដែលយល់ថាប្រជាជនដែលរស់នៅក្នុងទីក្រុងជាសសៃឈាមរបស់ពួកក្បត់ ដូច្នេះត្រូវជម្លៀសចេញ បំបែកចេញ និងសម្លាប់ពួកគេ ។ លោកព្រះរាជអាជ្ញាអន្តរជាតិ ខេលី បានលើកឡើងថា នួន ជា បានរៀបរាប់ថាការជម្លៀសឆ្នាំ១៩៧៥ ជាយុទ្ធសាស្ត្រកាត់ផ្តាច់ក្បាល និងកន្ទុយខ្មាំង ។ ខ្មាំងមានតិចនៅតាមជនបទ តែខ្មាំងមានច្រើននៅទីក្រុង ហេតុនេះត្រូវតែជម្លៀសនិងកម្ទេច ។ លោកព្រះរាជអាជ្ញាបន្ថែមថា ខៀវ សំផន បានលើកឡើងថា ជនបទជាគ្រឹះសំខាន់របស់បដិវត្តន៍ ទីក្រុងជាក្បាលម៉ាស៊ីនរបស់ខ្មាំងវណ្ណៈមូលធនត្រូវតែកម្ទេច (តាមរយៈទស្សនាវដ្តីទង់បដិវត្តន៍) ។ ការជម្លៀសប្រជាជនដើម្បីកម្ទេចបានធ្វើឡើងនៅទីតាំងឧក្រិដ្ឋកម្មខុសៗគ្នាដូចជា ៖

- ទួលកុលព្រៃ ជាការសម្លាប់នៅពោធិ៍សាត់ ដែលខ្មែរក្រហមប្រហារជីវិតមន្ត្រីរាជការ របស់ លន់ នល់ រាប់ពាន់នាក់ ។
- ទីលានមួយនៅកំពង់ឆ្នាំង ដែលសម្លាប់ខ្មាំងវណ្ណៈ ។

ជនជាប់ចោទបានបញ្ជាឲ្យសម្លាប់ទាហាន លន់ នល់ និងអំពាវនាវឲ្យប្រហារជីវិតមេដឹកនាំ៧រូប របស់ លន់ នល់ ក្នុងនោះមានជនមហាក្បត់ពីររូប គឺលោកនាយករដ្ឋមន្ត្រី ឡុង បូរ៉េត និងព្រះអង្គម្ចាស់ សិរី មតៈ ។ បក្សកុម្មុយនីស្តកម្ពុជាត្រូវបានគេមើលឃើញថាបានប្រព្រឹត្តឧក្រិដ្ឋកម្មតាំងពីដំបូង ។

### ៤) សហករណ៍ និងការដ្ឋាន

លោកព្រះរាជអាជ្ញាអន្តរជាតិ ខេលី បានអះអាងថា បន្ទាប់ពីជម្លៀសប្រជាជនចេញពីទីក្រុង ខ្មែរក្រហមបានបញ្ជូនប្រជាជនទាំងនោះឲ្យទៅធ្វើជាទាសករនៅតាមបណ្តាការដ្ឋាននៅទីជនបទនៅក្រោយពេលដែលខ្មែរក្រហមចូលកាន់តំណែង ។ បក្សកុម្មុយនីស្តកម្ពុជាបានឯកភាពទៅលើផែនការសហករណ៍ ថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៣ ដើម្បីបង្កើតអង្គការសហករណ៍កសិករ និងធ្វើការលុបបំបាត់ទីផ្សារ ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កម្ពុជាទាំងមូលបានក្លាយទៅជាគុកឥតជញ្ជាំង និងការដ្ឋានដាច់កន្ទុយភ្នែក ។ នៅក្រោយការជម្លៀសនៅឆ្នាំ១៩៧៦ ជនរងគ្រោះ២ម៉ឺននាក់បានស្លាប់បាត់បង់ជីវិត ហើយប្រជាជនជាច្រើនទៀតបានស្លាប់ជាបន្តបន្ទាប់ ដោយសារតែគោលនយោបាយរបស់ខ្មែរក្រហមដែលត្រូវសម្រេចឲ្យបានទិន្នផលស្រូវ៣តោនក្នុងមួយហិតា ។ គេមិនបានគិតគូរផលវិបាកនានាដែលកើតឡើងនៅក្នុងអំឡុងពេលនោះឡើយ ដូចជាការមិនធ្លាក់ភ្លៀងនៅតំបន់ខ្លះ ការបំផ្លាញដោយ

សារសត្វចង្រៃ កណ្តុរកាត់ បើសម្រេចមិនបាននឹងត្រូវមានទោស ។ ចំពោះការដ្ឋានកសាងទំនប់នានា គេបានប្រើគោលនយោបាយមហាលោតផ្លោះ មហាអស្ចារ្យ ដោយតម្រូវឲ្យអ្នកធ្វើការទាំងអស់សម្រេចឲ្យបានផែនការ នោះក្នុងរយៈពេលមួយដ៏ខ្លី ។ ដូចជាទំនប់ធំៗពីរគឺ ទំនប់១មករា នៅខេត្តកំពង់ធំ និងទំនប់ត្រពាំងថ្ម នៅខេត្តបន្ទាយមានជ័យជាដើម ។ ទំនប់១មករាមានទំហំធំ តែគោលនយោបាយរបស់បក្សកុម្មុយនីស្ត គឺត្រូវធ្វើមិនឲ្យលើសពី១ឆ្នាំ ការធ្វើការងារអាក្រក់បំផុត គឺចាប់ពីម៉ោង៥ ព្រឹកដល់ម៉ោង១០ យប់ គ្មានអាហារហូបចុកគ្រប់គ្រាន់និងគ្មានថ្នាំសង្កូវ បានបណ្តាលឲ្យប្រជាជនស្លាប់យ៉ាងច្រើន ។ ការកសាងទំនប់ទាំងនោះត្រូវបានធ្វើឡើងដោយដៃទទេ ។ ជនជាប់ចោទបានដឹងពីស្ថានភាពអមនុស្សធម៌នៅតាមកន្លែងឧក្រិដ្ឋកម្មទាំងនោះ ។ លោកព្រះរាជអាជ្ញាបានលើកឡើងថា ជនជាប់ចោទបានទៅពិនិត្យកន្លែងទាំងអស់នោះ ។ ជនជាប់ចោទ នួន ជា អៀង សារី និង ខៀវ សំផន ក៏ធ្លាប់បានធ្វើទស្សនកិច្ចការដ្ឋាន១មករាដែរ ។ អៀង សារី បានប្រើការដ្ឋាននៅខេត្តសៀមរាបដើម្បីដាក់ទណ្ឌកម្មទៅលើបុគ្គលិករបស់ក្រសួងការបរទេស ។ នៅក្នុងកិច្ចប្រជុំដែលមានវត្តមាន នួន ជា និងខៀវ សំផន មានការរាយការណ៍ពីភូមិភាគ និងស្ថានភាពនៅការដ្ឋានដូចជា ជំងឺអាសន្នរោគ អុចស្វាយ និងប្រជាជនស្លាប់ប្រមាណជា៤០ភាគរយ ។ ទោះបីជាជនជាប់ចោទធ្លាប់បានដឹងឮពីការលំបាក និងការកើតមានជំងឺឆ្លងនៅក្នុងការដ្ឋាននានា ជនជាប់ចោទនៅតែបង្ខំឲ្យប្រជាជនត្រូវបង្កើនចំនួនទិន្នផលរបស់ខ្លួនដើម្បីធ្វើការនាំចេញ ។

### ៥) ការចូលរួមរបស់ជនជាប់ចោទក្នុងអំពើឧក្រិដ្ឋកម្ម

#### ◆ ជនជាប់ចោទ ខៀវ សំផន

សហព្រះរាជអាជ្ញាអន្តជាតិ អេនទ្រូ ខេលី បានលើកឡើងថា ខៀវ សំផន បានបញ្ជាក់នៅក្នុងចម្លើយសារភាពរបស់ខ្លួនថា "ខ្លួនមិនបានដឹងពីការចាប់ខ្លួនណាមួយ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ" នោះគឺជាការភូតភរកុហកមួយដែលមិនអាចទទួលយកបាន ព្រោះខ្លួនមានភស្តុតាងគ្រប់គ្រាន់ដែលអាចបញ្ជាក់ថា ខៀវ សំផន បានដឹង ។ ព្រះរាជអាជ្ញាបន្ថែមថា ខៀវ សំផន បានដឹងយ៉ាងច្បាស់ពីការសម្រេចរបស់គណៈមជ្ឈិមក្នុងការកាប់សម្លាប់មនុស្សតាមរយៈសារទូរលេខ និងរបាយការណ៍សារភាពនានាពីមន្ទីរ៨៧០ ព្រោះ ខៀវ សំផន និង ឌឿន ជាគណៈគ្រប់គ្រងនៅមន្ទីរ៨៧០ ។ នៅក្នុងកិច្ចប្រជុំគណៈកម្មការអចិន្ត្រៃយ៍ ថ្ងៃទី៣០ មីនា ១៩៧៦ បានចេញសេចក្តីសម្រេចផ្តល់អំណាចឲ្យទៅមន្ទីរ៨៧០ ធ្វើការកម្ទេចខ្មាំងនៅជុំវិញមន្ទីរនេះ ។ ខៀវ សំផន គ្រប់គ្រងមន្ទីរ៨៧០ តែម្នាក់ឯងក្រោយពេល ឌឿន បានបាត់ខ្លួន ។ បន្ទាប់មកមុខងាររបស់ ឌឿន ត្រូវបានជំនួសដោយ ឈ្មោះ ប៉ាំង ។ ខៀវ សំផនក៏ធ្លាប់បាន រៀបរាប់នៅក្នុងវគ្គបំពាក់បំប៉នយោបាយថា ប៉ាំង ត្រូវបានគេសម្លាប់ដោយសារជាតិញរបស់វៀតណាម ។ ខៀវ សំផន ធ្លាប់បានចូលរួមយ៉ាងសកម្មក្នុងការកម្ចាត់ខ្មាំង ហើយក៏ធ្លាប់បានធ្វើអន្តរាគមន៍រារាំងមិនឲ្យសម្លាប់បងប្អូនរបស់ខ្លួន ។ នេះសបញ្ជាក់ថា ជនជាប់ចោទ ខៀវ សំផន មានសិទ្ធិគ្រប់គ្រាន់ក្នុងការរារាំងមិនឲ្យគេសម្លាប់នរណាម្នាក់បាន ។

#### ◆ ជនជាប់ចោទ អៀង សារី

ព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា ជនជាប់ចោទ អៀងសារី បានចូលរួមប្រជុំអនុម័តលើសេចក្តីសម្រេចចុះថ្ងៃទី៣០ មីនា ១៩៧៦ ដែលសេចក្តីសម្រេចនេះផ្តល់អំណាចដល់ថ្នាក់ក្រោមមានសិទ្ធិធ្វើសេចក្តីសម្រេចកម្ទេចខ្មាំងក្នុងជួរបក្ស ។ តាមរយៈសេចក្តីសម្រេចនេះបានបង្ហាញពីចេតនាយ៉ាងជាក់លាក់របស់ជនជាប់ចោទក្នុងការអនុវត្តគោលនយោបាយកាប់សម្លាប់មនុស្ស ។ បន្ថែមលើនេះ អៀង សារី មានសិទ្ធិក្នុងការកំណត់ថានរណាដែលត្រូវចាប់ខ្លួន និងនរណាដែលមិនត្រូវចាប់ខ្លួន ដោយសារ អៀង សារី ធ្លាប់បានរារាំងមិនឲ្យខ្មែរក្រហមសម្លាប់មិត្តភក្តិជិតដិតរបស់ខ្លួនដែលធ្លាប់រៀនសូត្រជាមួយគ្នា ។ ក្រសួងការបរទេសរបស់ អៀង សារី ត្រូវបានប្រើប្រាស់សម្រាប់រក្សាកម្មាភិបាលដែលត្រូវបានសង្ស័យ ឬហៅម្យ៉ាងទៀតថាកន្លែងរង់ចាំសេចក្តីស្លាប់ ។ និស្សិត បញ្ញវ័ន្ត ដែលរស់នៅក្រៅប្រទេសជាច្រើនត្រូវបានគេបោកបញ្ឆោតឲ្យចូលមកប្រទេសកម្ពុជាតាមរយៈក្រសួងការបរទេស ហើយអ្នកទាំងនោះត្រូវបានសម្លាប់ចោលឬដាក់ក្នុងមន្ទីរឃុំឃាំង ។ ទាំងនេះបង្ហាញថា អៀង សារី ដឹងអំពីឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

#### ◆ ជនជាប់ចោទ នួន ជា

សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា ភស្តុតាងបាន

បង្ហាញហួសពីវិមតិសង្ស័យថា នួន ជា បានពាក់ព័ន្ធដោយផ្ទាល់ក្នុង ការបោសសម្អាតជនក្បត់នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ។ នួន ជា អ្នកទទួលបន្ទុកកិច្ចការបក្សនិងជាអ្នកទទួលបន្ទុកសន្តិសុខទាំងមូល ។ អៀង ធីរិទ្ធ ក៏ធ្លាប់បានបញ្ជាក់ដែរថា នួន ជា បានចាប់ខ្លួនកូនសិស្ស របស់គាត់ពីក្រសួងដែលគាត់គ្រប់គ្រងយកទៅសម្លាប់ចោល ។ ឌុច ធ្លាប់បានរាយការណ៍ថា នួន ជា បានបញ្ជាដោយផ្ទាល់ឲ្យគេដុត សម្លាប់មនុស្សទាំងរស់នៅក្នុងមន្ទីរស-២១ ហើយឌុច តែងតែជួប នួន ជា ៣ទៅ៥ថ្ងៃម្តង ដើម្បីផ្តល់ចម្លើយសារភាពទៅគណៈមជ្ឈិម និងទទួលសេចក្តីសម្រេចឲ្យចាប់ខ្លួន។ នួន ជា ធ្លាប់បានធ្វើចំណារ នៅក្នុងចម្លើយសារភាពដើម្បីបញ្ជាឲ្យគេយកទៅអនុវត្តនិងចាប់ខ្លួន ជនដែលត្រូវបានគេឆ្លើយដាក់នៅទូទាំងប្រទេស ។ ព្រះរាជអាជ្ញា បន្ថែមថា ជនជាប់ចោទ នួន ជា បានដឹងយ៉ាងច្បាស់ពីការអនុវត្ត គោលនយោបាយកម្ទេចរបស់បក្សកុម្មុយនីស្តកម្ពុជា ព្រោះ នួន ជា បានអះអាងថា នៅក្នុងបក្សកុម្មុយនីស្តមានជនបង្កប់ខ្លួនយ៉ាងច្រើន ដូចជា សេ អ៊ី អា និង កា ហ្សេ បេ ។ នៅក្នុង កិច្ចសម្ភាសមួយឆ្នាំ ២០០៥ នួន ជា បានលើកឡើងថា «យើងសម្លាប់តែសមាសភាព មិនល្អតែប៉ុណ្ណោះ ពួកក្បត់ទាំងនោះមិនបានដើរតាមមាគ៌ារបស់ យើង» ។ ជនជាប់ចោទនីមួយៗបានចូលរួមយ៉ាងសកម្មនិងផ្ទាល់ នៅក្នុងឧក្រិដ្ឋកម្មទាំងនេះ ។

### ២) សេចក្តីឆ្លើយតបរបស់ជនជាប់ចោទទៅនឹងសេចក្តីសន្និដ្ឋានចោទប្រកាន់របស់សហព្រះរាជអាជ្ញា

បន្ទាប់ពីការបញ្ចប់សេចក្តីសន្និដ្ឋានចោទប្រកាន់របស់សហព្រះរាជអាជ្ញា ក្រុមមេធាវីរបស់ជនជាប់ចោទ នួន ជា ត្រូវបានអង្គជំនុំជម្រះផ្តល់ឱកាសឲ្យធ្វើសេចក្តីឆ្លើយតបទៅនឹងចោទប្រកាន់របស់សហព្រះរាជអាជ្ញាមុនជនជាប់ចោទដទៃទៀត ប៉ុន្តែសហមេធាវីរបស់ជនជាប់ចោទរូបនេះមិនបានឡើងដោយសេចក្តីឆ្លើយតបដោយផ្ទាល់នោះទេ គឺរូបជនជាប់ចោទ នួន ជា ជាអ្នកដែលបានឡើងថ្លែងសេចក្តីថ្លែងការណ៍របស់ខ្លួន ដែលអង្គជំនុំជម្រះចាត់ទុកថាគឺជាការឆ្លើយតបរបស់ជនជាប់ចោទ នួន ជា ទោះបីជានៅក្នុងសេចក្តីថ្លែងការណ៍នោះភាគច្រើនផ្តោតសំខាន់ទៅលើការឈ្លានពានរបស់ប្រទេសវៀតណាម និងការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកយ៉ាងណាក្តី ។

#### ក) សេចក្តីថ្លែងការណ៍របស់ជនជាប់ចោទ នួន ជា



នួន ជា ក្នុងបន្ទប់សវនាការ (រូបថត ៖ អ.វ.ត.ក)

នៅរសៀលថ្ងៃទី២នៃសវនាការ ជនជាប់ចោទ នួន ជា បានឡើងអានសេចក្តីថ្លែងការណ៍ដោយ ផ្ទាល់នៅក្នុងវង្វង់ក្រចកសេះ ដើម្បីធ្វើការឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានចោទប្រកាន់របស់សហព្រះរាជអាជ្ញាមកលើខ្លួន។ នៅពេលចាប់ផ្តើមធ្វើសេចក្តីថ្លែងការណ៍របស់ខ្លួន ជនជាប់ចោទ នួន ជា បានសម្តែងនូវការគោរពទៅដល់ជនរួមជាតិ ជាពិសេសចំពោះវិញ្ញាណក្ខន្ធរបស់អ្នកដែលបានពលីជីវិតដើម្បីជាតិមាតុភូមិ ។ ពាក្យចាប់ផ្តើមដំបូងនៅក្នុងសេចក្តីថ្លែងការណ៍គឺ «ការមិនពេញចិត្តចំពោះតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម» ជនជាប់ចោទ នួន ជា បានលើកឡើងថា តុលាការនេះមិនមានភាពយុត្តិធម៌សម្រាប់ខ្លួនឡើយ ព្រោះតុលាការនេះលើកយកតែហេតុការណ៍ដែលបានកើតឡើងក្នុងអំឡុងឆ្នាំ ១៩៧៥ដល់១៩៧៩ប៉ុណ្ណោះ ដោយមិនព្រមពិភាក្សាចំពោះឫសគល់ និងបច្ច័យដែលបានកើតឡើងមុននឹងក្រោយរយៈពេលនេះឡើយ ។ ជនជាប់ចោទរូបនេះបានលើកឡើងថា «ក្រពើមួយទាំងមូលគេយកតែខ្លួនមកនិយាយ ដោយមិនបានពិភាក្សាអំពីក្បាលនិងកន្ទុយដែលជាផ្នែកបម្រើដល់សកម្មភាពប្រចាំថ្ងៃរបស់វាឡើយ» ។ ទោះបីជាបានដឹងថាសហព្រះរាជអាជ្ញាចោទប្រកាន់មកលើខ្លួនចំពោះអំពើឧក្រិដ្ឋកម្មដែលកើតឡើងក្នុងចន្លោះឆ្នាំ ១៩៧៥ដល់ឆ្នាំ១៩៧៩ តែជនជាប់ចោទរូបនេះបានធ្វើការឆ្លើយតបតិចតួចពាក់ព័ន្ធនឹងការជម្លៀស និងការសម្លាប់ប្រជាជននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ អ្វីដែលជនជាប់ចោទ នួន ជា



នួន ជា ថ្លែងសុន្ទរកថាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ប្រភព ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បានប្រើពេលវេលាយ៉ាងច្រើនក្នុងការធ្វើសេចក្តីថ្លែងការណ៍របស់ខ្លួនគឺព្រឹត្តការណ៍ដែលកើតឡើងមុនឆ្នាំ១៩៧៥ ដែលព្រឹត្តការណ៍ទាំងនេះត្រូវបានជនជាប់ចោទរូបនេះអះអាងថាជាដើមហេតុដែលនាំឲ្យកើតមានរបបកម្ពុជាប្រជាធិបតេយ្យ ។ ជនជាប់ចោទ នួន ជា បានលើកឡើងនូវព្រឹត្តការណ៍ទាំងនោះដោយសង្ខេបថា នៅក្នុងចលនាទាមទារឯករាជ្យពីបារាំង បក្សកុម្មុនីស្តនៅឥណ្ឌូចិនមួយត្រូវបានបង្កើតឡើងក្រោមការដឹកនាំរបស់ហូជីមិញ ។ នៅក្នុងបក្សកុម្មុយនីស្តឥណ្ឌូចិនមានរួមមានបក្សកុម្មុយនីស្តកម្ពុជា បក្សកុម្មុយនីស្តឡាវ និងបក្សពលករវៀតណាម ។ ជនជាប់ចោទរូបនេះបានលើកឡើងថា បក្សកុម្មុយនីស្តកម្ពុជា និងបក្សកុម្មុនីស្តឡាវមិនមានឯករាជ្យពីវៀតណាមឡើយ ហើយវៀតណាមមានបំណងគ្រប់គ្រងសហព័ន្ធឥណ្ឌូចិនទាំងមូល ដោយវៀតណាមបានលួចបង្កើតបក្សមួយដោយសម្ងាត់នៅក្នុងប្រទេសរបស់ខ្លួនហៅថា «បក្សប្រជាជនកម្ពុជា» ។ សមាជិករបស់បក្សនេះ គឺពួកខ្មែរវៀតមិញដែលវៀតណាមយកទៅអប់រំនៅហាណូយតាំងពីឆ្នាំ១៩៥៤ ក្រោយកិច្ចព្រមព្រៀងហ្សឺណែវ ។ ជនជាប់ចោទបន្តទៀតថា ពួកនេះទៅរៀននៅវៀតណាម១៦ឆ្នាំទទួលឥទ្ធិពល ទស្សនៈ គោលជំហរមាគ៌ានយោបាយ មាគ៌ាចាត់តាំងពីបក្សកុម្មុយនីស្តវៀតណាម ហើយយកមកអនុវត្តផ្សព្វផ្សាយនៅកម្ពុជា និងថែមទាំងវាយប្រហារមាគ៌ានយោបាយ មាគ៌ាចាត់តាំង យុទ្ធវិធីរបស់បក្សកុម្មុយនីស្តកម្ពុជាជាបន្តបន្ទាប់មកពិសេសតាំងពីឆ្នាំ១៩៦០ ។

ព្រឹត្តការណ៍មួយទៀតដែលជនជាប់ចោទ នួន ជា បានលើកឡើងគឺការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកមកលើប្រទេសកម្ពុជាក្នុងអំឡុងឆ្នាំ១៩៧៣ ។ ជនជាប់ចោទរូបនេះបានលើកឡើងថាក្នុងខែសីហា ឆ្នាំ១៩៧៣ សហរដ្ឋអាមេរិកបានទម្លាក់គ្រាប់បែកបេ៥២មកលើទឹកដីកម្ពុជាយ៉ាងសាហាវឃោរឃៅ ។ ក្នុងរយៈពេលចាប់ពីខែកុម្ភៈដល់ខែសីហា ឆ្នាំ១៩៧៣ សហរដ្ឋអាមេរិកបានទម្លាក់គ្រាប់បែកបេ៥២ជាច្រើនម៉ឺនតោនមកលើប្រទេសកម្ពុជាជាប់ៗគ្នាអស់រយៈពេល២០០ថ្ងៃ២០០យប់ ។ លទ្ធផលនៃការទម្លាក់គ្រាប់បែកនេះបានបំផ្លាញផលដំណាំ ទ្រព្យសម្បត្តិ និងបានសម្លាប់ប្រជាជនកម្ពុជា ជាច្រើន ។

ក្រោយពីរំដោះបានទីក្រុងភ្នំពេញ ជនជាប់ចោទ នួន ជា បានលើកឡើងថា «នៅខែមិថុនា ឆ្នាំ១៩៧៥ គណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាបានបញ្ជូនគណៈកម្មការជាន់ខ្ពស់របស់ខ្លួនទៅទីក្រុងហាណូយប្រទេសវៀតណាម ។ នៅពេលទៅដល់មេបញ្ជាការកងទ័ពប្រជាជនវៀតណាម ឈ្មោះ វ៉ងង្វៀនយ៉ាប បានសួរ ប៉ុល ពត ថាតើដីកម្ពុជាអាចបង្កើនផលបានប៉ុន្មានហិកតា? ប៉ុល ពត ថា ប្រហែលជា៨លានហិចតា តែដីដែលល្អមានប្រហែលជាង៣លានហិចតា ។ វ៉ងង្វៀនយ៉ាប ថា «ង៉នវ៉ា» ដែលមានន័យជាភាសាខ្មែរគឺ «ឆ្ងាញ់ណាស់» ។ ជនជាប់ចោទរូបនេះបានបន្តថា នៅពេលដែលឮពាក្យ «ង៉នវ៉ា» នេះ ខ្លួនគិតថា ផាម វ៉ាន់ដុង (នាយករដ្ឋមន្ត្រីរបស់វៀតណាម) និង វ៉ងង្វៀនយ៉ាប គឺសុទ្ធតែមានអត្តន័យស៊ីជម្រៅ ។

ព្រឹត្តិការណ៍មួយទៀតដែលជនជាប់ចោទ នួន ជា បានលើកយកមកបង្ហាញនៅក្នុងសេចក្តីថ្លែងការណ៍របស់ខ្លួនគឺការចាប់ខ្លួនលោក ប៉ែន សុវណ្ណ (អតីតនាយករដ្ឋមន្ត្រីសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា) ដាក់គុកនៅទីក្រុងហាណូយ ប្រទេសវៀតណាម នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ១៩៨១ ។ ជនជាប់ចោទរូបនេះបានដកស្រង់សម្តីរបស់លោក ឡេ ឌឹកថូ (សមាជិកការិយាល័យនយោបាយនៃបក្សកុម្មុនីស្តវៀតណាម) ដែលបានស្តីបន្ទោសឲ្យលោក ប៉ែន សុវណ្ណ ថ្លែងប្រាប់អង្គជំនុំជម្រះដោយលើកឡើងថា លោក ឡេ ឌឹកថូ បានលើកដៃចង្អុលមុខ លោក ប៉ែន សុវណ្ណ ហើយចេញសម្តីខ្លាំងៗថា «ខ្ញុំស្មានមិនបានថាអ្នកឯងហ៊ានប្រឆាំងជាមួយនឹងខ្ញុំ ។ អ្នកឯងដឹងទេសព្វថ្ងៃកងទ័ពរបស់ខ្ញុំមាន និងកំពុងនៅលើទឹកដីអ្នកឯងចំនួន ១៨,០០០នាក់ ។ អ្នកឯងកុំស្មានថាចង់ដោះស្រាយវាសនារបស់ប្រទេសអ្នកឯងបានតាមទំនើងចិត្ត ។ ពិតមែនប្រទេសអ្នកឯងបានចាត់តាំងជាប្រទេសរចនាសម្ព័ន្ធភាវូបនីយបក្សមែនពិត ប៉ុន្តែមិនហួសពីរង្វង់ដៃរបស់យើងខ្ញុំទេ ។ អ្នកឯងចាំមើលថ្ងៃក្រោយទោះបីគ្មានកងទ័ពយើងខ្ញុំនៅប្រចាំក្នុងប្រទេសអ្នកឯងក៏ដោយ បើមានអ្នកណាហ៊ានកម្រើកចេញពីរង្វង់ដៃរបស់យើងខ្ញុំ យើងខ្ញុំនឹងប្រាប់ឲ្យម៉ង្ហ ។ អ្នកឯងបានរៀនទ្រឹស្តីច្រើនជាងគេទាំងអស់ ប៉ុន្តែពេលអ្នកឯងកាន់អំណាច អ្នកឯងកសាងប្រទេស កសាងសេដ្ឋកិច្ចជាតិងាកចេញពីរបបកុម្មុយនីស្ត និងបោះបង់ចោលលទ្ធិសង្គមនិយម ។ នេះហើយដែលរាល់អ្នកជំនាញការរបស់យើងខ្ញុំដែលចុះទៅ

ជំនួយ នៅប្រទេសអ្នកឯងគេមិនហ៊ានធ្វើអ្វីតាមអ្នកឯង ព្រោះអ្នកឯងប្រាសចាកក្រឹត្យក្រមសេដ្ឋកិច្ចសង្គមនិយម ។ ព្រោះតែមូលហេតុនេះហើយ បានជាបក្សរបស់អ្នកឯងបណ្តេញ និងបដិសេធមិនព្រមឲ្យអ្នកឯងដឹកនាំបក្ស និងរដ្ឋាភិបាល ។ គេធ្វើដូច្នេះហើយ ទើបសមនឹងអំពើអ្នកឯងដែលដឹកនាំអនុវត្តខុសគន្លងសង្គមនិយម ។ ដោយទោសកំហុសទាំងនេះ ខ្ញុំសូមប្រកាសឲ្យអ្នកឯង រស់នៅទីនេះ ហើយគ្មានសិទ្ធសេរីភាពទាំងអស់អស់មួយជីវិត» ។

ក្រោយពីជនជាប់ចោទ នួន ជា បង្ហាញពីព្រឹត្តការណ៍មួយចំនួនដែលខ្លួនគិតថា ប្រទេសវៀតណាមមានបំណងឈ្លានពាន និងគ្រប់គ្រងលើប្រទេសកម្ពុជា ជនជាប់ចោទរូបនេះក៏បានបង្ហាញពីមូលហេតុដែលនាំឲ្យមានការជម្លៀសនិងការកាប់សម្លាប់ប្រជាជនកម្ពុជានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យផងដែរ ។ ជនជាប់ចោទ នួន ជា បានលើកឡើងថា កិច្ចប្រជុំមិនពេញអង្គមួយត្រូវបានបក្សកុម្មុយនីស្តធ្វើឡើងកាលពីពាក់កណ្តាលឆ្នាំ១៩៧៤ ។ កិច្ចប្រជុំនេះធ្វើការពិភាក្សាពីលទ្ធភាពដែលអាចកើតឡើង និងធ្វើឲ្យប៉ះពាល់ដល់បក្សកុម្មុយនីស្តកម្ពុជាក្រោយពេលដែលបក្សនេះទទួលបានជ័យជម្នះ ។ ជនជាប់ចោទរូបនេះបានបន្តថា អង្គប្រជុំបានសម្រេចថានឹងធ្វើការជម្លៀសប្រជាជនចេញពីទីក្រុងដោយហេតុថា នៅទីក្រុងភ្នំពេញមានប្រជាជនប្រមាណជាង៣លាននាក់ ដែលក្នុងនោះមានប្រជាជនប្រមាណជា៩០ភាគរយ ហូបមិនគ្រប់គ្រាន់ ហើយប្រជាជនមួយចំនួនទៀតអត់អាហារស្លាប់ជាបណ្តើរៗទៅហើយ ។ ម្យ៉ាងវិញទៀតសហករណ៍នៅតាមមូលដ្ឋានក៏មានការខ្វះខាតកម្លាំងពលកម្មក្នុងការបង្កបង្កើនផល ដោយសារយុវជននិងយុវនារីដែលជាប្រជាជនមូលដ្ឋានភាគច្រើនទៅធ្វើកងទ័ពអស់២ភាគ៣ គឺនៅសល់តែកម្លាំងមនុស្សចាស់ដែលធ្វើពលកម្មមិនបានពេញលេញ ។

បញ្ហាសំខាន់មួយទៀតដែលជនជាប់ចោទ នួន ជា បានលើកឡើងថា អង្គប្រជុំបានយកមកពិភាក្សា គឺការបំផ្លិចបំផ្លាញវិទ្ធង្សនារបស់កងទ័ព លន់ នល់ នៅទីក្រុងភ្នំពេញ និងពួកបាក់ទ័ពដែលរត់ទៅជ្រកនៅជាយដែនថៃនិងវៀតណាមខាងត្បូង ។ អង្គប្រជុំយល់ឃើញថា បើបក្សកុម្មុយនីស្តកម្ពុជារំដោះបានទីក្រុងភ្នំពេញ កងទ័ពរបស់ លន់ នល់ ដែលភាគច្រើនជាខ្មែរសេរី មុខជាបែកខ្ញាត់ខ្ញាយដោយមួយចំនួនសម្ងំនៅក្នុងទីក្រុង ហើយមួយចំនួនរត់ទៅព្រំដែនថៃ ។ កងទ័ពដែលបែកខ្ញាត់ខ្ញាយទាំងនេះនឹងគ្មានអ្វីសម្រាប់ផ្គត់ផ្គង់ជីវភាពនោះទេ ហើយប្រាកដជាលួច ឆក់ ប្លន់ សម្លាប់មនុស្ស និងដុតផ្ទះសម្បែងប្រជាជនជាមិនខាន ។ ជនជាប់ចោទ នួន ជា បានបន្ថែមថា បន្ទាប់ពីរំដោះបានទីក្រុងភ្នំពេញនៅខែមេសា ឆ្នាំ១៩៧៥ មានទាហាន លន់ នល់ មួយចំនួនស្លៀកខោពាក់ខោបន្លំធ្វើដូចជាកងទ័ពបដិវត្តកម្ពុជាបានចាប់អ្នករាជការ សម័យ លន់ នល់ មន្ត្រីស៊ីវិល ទាហាន ដោយបោកបញ្ឆោតថាទៅគាល់សម្តេចសីហនុ ប៉ុន្តែបែរជាយកពួកទាំងនោះទៅសម្លាប់ចោល ។ ម្យ៉ាងទៀតថែមទាំងបោកបញ្ឆោតបងប្អូនរបស់កម្មាភិបាលបដិវត្តកម្ពុជាយកទៅសម្លាប់ចោលទាំងគ្រួសារថែមទៀតផង ។

ពាក់ព័ន្ធនឹងការលុបបំបាត់ទីផ្សារ ប្រាក់កាស ជនជាប់ចោទ នួន ជា បានលើកឡើងពីទស្សនៈយល់ឃើញរបស់បក្សកុម្មុយនីស្តថា លុយគឺជាអាវុធសំខាន់ និងមានប្រសិទ្ធភាពណាស់របស់ខ្មាំង ។ តាមពិសោធកន្លងមក ការដែលបក្សមិនចាយលុយនៅក្នុងតំបន់រំដោះរបស់ខ្លួន ធ្វើឲ្យបក្សអាចរក្សាការពារបានតំបន់រំដោះដ៏ធំទូលាយ ។ ខ្មាំងមិនអាចវាយដណ្តើមយកតំបន់រំដោះពីខ្លួនបានឡើយ ផ្ទុយទៅវិញខ្លួនកាន់តែពង្រីកតំបន់រំដោះបានកាន់តែធំ ។ ពួកចារកម្មក៏មិនអាចយកលុយមកទិញកម្មាភិបាលពីកងទ័ពរបស់បក្សបានដែរ ។ ជនជាប់ចោទបានបន្ថែមថា ការប្រើយុទ្ធវិធីមិនចាយលុយវាប៉ះពាល់ប្រជាជនអ្នកមានលុយចំនួនតិច ឯប្រជាជនកសិករទូទៅជាពិសេសកសិករក្រីក្រមិនមានប៉ះពាល់ឡើយ ។

សរុបសេចក្តីមក សេចក្តីថ្លែងការណ៍របស់ជនជាប់ចោទ នួន ជា នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ភាគច្រើនផ្តោតសំខាន់តែទៅលើព្រឹត្តការណ៍ដែលបានកើតឡើងមុនរបបកម្ពុជាប្រជាធិបតេយ្យតែប៉ុណ្ណោះ ។ ជនជាប់ចោទរូបនេះ ហាក់ដូចជាចង់ទម្លាក់កំហុសទាំងស្រុងទៅលើរបបដែលកើតមុនរបបកម្ពុជាប្រជាធិបតេយ្យ ។ ជាក់ស្តែងជនជាប់ចោទ នួន ជា បានអះអាងថា «អ្វីៗដែលខ្ញុំធ្វើ គឺជាការលះបង់ដើម្បីផលប្រយោជន៍ប្រទេសជាតិ ដោយហេតុថាខ្ញុំបានមើលឃើញការរស់នៅក្រោមការគាបសង្កត់ និងមើលឃើញភាពអយុត្តិធម៌នៅក្នុងសង្គមបានជំរុញឲ្យខ្ញុំមានគំនិតបោះបង់គ្រួសារដើម្បីតស៊ូរំដោះជាតិមាតុភូមិចេញពីនឹមអាណានិគម គឺលុបបំបាត់ការឈ្លានពានពីចោរបរទេសលេបទឹកដី ចង់

លុបបំបាត់ព្រះពុទ្ធសាសនា និងពូជសាសន៍ខ្មែរ» ។

ជនជាប់ចោទ នួន ជា ធ្វើការឆ្លើយតបតិចតួច ប៉ុន្តែមិនឆ្លើយតបទៅនឹងការចោទប្រកាន់ របស់សហព្រះរាជអាជ្ញាគឺព្រឹត្តការណ៍ដែលកើតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ឧទាហរណ៍ ការចោទប្រកាន់របស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងការបង្ខំឲ្យប្រជាជនធ្វើការ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ការចោទពីអំពើប្រល័យពូជសាសន៍លើជនជាតិចាម និងវៀតណាមជាដើម ។

### ១) សេចក្តីថ្លែងការណ៍របស់ជនជាប់ចោទ អៀង សារី



អៀង សារី ក្នុងបន្ទប់សវនាការ (រូបថត : អ.វ.ត.ក)

នៅថ្ងៃទី៣នៃសវនាការ គឺជាថ្ងៃដែលអង្គជំនុំជម្រះផ្តល់ឲ្យមេធាវីរបស់ជនជាប់ចោទ អៀង សារី ធ្វើការឆ្លើយតបទៅនឹងការចោទប្រកាន់របស់សហព្រះរាជអាជ្ញា ។ សហមេធាវីជាតិរបស់ជនជាប់ចោទ អៀង សារី គឺលោកមេធាវី អាង ឧត្តម បានថ្លែងថា កូនក្តីរបស់ខ្លួននឹងមិនធ្វើការឆ្លើយតបទៅនឹងការចោទប្រកាន់របស់សហព្រះរាជអាជ្ញាឡើយ ។ មេធាវីបានលើកឡើងថាមូលហេតុដែលខ្លួននិងកូនក្តីរបស់ខ្លួនមិនឆ្លើយតបនេះ ដោយហេតុថាសហព្រះរាជអាជ្ញាមិនបានបង្ហាញសាក្សី និងភ័ស្តុតាងឲ្យបានច្បាស់លាស់ ដែលអាចឲ្យមេធាវីការពារក្តីរកមើលបាន ហើយសាក្សីនិងភ័ស្តុតាងទាំងនោះក៏មិនដឹងថាតុលាការបានទទួលស្គាល់ឬនៅក៏មិនដឹង ។

ទោះបីជាមេធាវីការពារក្តីរបស់ អៀង សារី មិនធ្វើការឆ្លើយតបទៅនឹងការចោទប្រកាន់របស់សហព្រះរាជអាជ្ញាក៏ដោយ ជនជាប់ចោទ អៀង សារី បានធ្វើសេចក្តីថ្លែងការណ៍នៅក្នុងសវនាការទាក់ទងនឹងការលើកលែងទោស និងអនុគ្រោះទោសដែលបានផ្តល់ឲ្យដោយអតីតព្រះមហាក្សត្រ នរោត្តម សីហនុ ។ ជនជាប់ចោទ អៀង សារី បានលើកឡើងថា នៅឆ្នាំ១៩៩៦ ខ្លួនត្រូវបានអតីតព្រះមហាក្សត្រ នរោត្តម សីហនុ បានលើកលែងទោស និងអនុគ្រោះទោសដោយមានការអនុម័តយល់ព្រមពីរដ្ឋសភា និងចុះហត្ថលេខាដោយព្រះមហាក្សត្រ ។ ជនជាប់ចោទ អៀង សារី បានបន្ថែមថា អស់រយៈពេលជាង៤ឆ្នាំដែលខ្លួនរង់ចាំការជំនុំជម្រះទោស តែអង្គជំនុំជម្រះនៅមិនទាន់បានដោះស្រាយបញ្ហាផ្លូវច្បាប់ពាក់ព័ន្ធនឹងអញ្ញត្រកម្មដែលខ្លួនបានដាក់ឲ្យបានរួចរាល់នៅឡើយ ។ ដូចនេះខ្លួនមិនមានបំណងចូលរួមក្នុងសវនាការឡើយ ដរាបណាអញ្ញត្រកម្មស្តីពីការលើកលែងទោស និងអនុគ្រោះទោសនេះមិនទាន់បានសម្រេចជាស្ថាពរដោយតុលាការកំពូល ។ ប៉ុន្តែ ជនជាប់ចោទ អៀង សារី បានបន្ថែមថា ដោយការគោរពចំពោះតុលាការនេះ ខ្លួននឹងនៅតែចូលរួមនៅក្នុងសវនាការនេះបន្តទៀត ។

### ក) សេចក្តីថ្លែងការណ៍របស់ជនជាប់ចោទ ខៀវ សំផន



ខៀវ សំផន ក្នុងបន្ទប់សវនាការ (រូបថត : អ.វ.ត.ក)

ជនជាប់ចោទ ខៀវ សំផន ត្រូវបានអង្គជំនុំជម្រះអនុញ្ញាតឲ្យឡើងអានសេចក្តីថ្លែងការណ៍របស់ខ្លួនឆ្លើយតបទៅនឹងការចោទប្រកាន់របស់សហព្រះរាជអាជ្ញានៅក្នុងរង្វង់ក្រចកសេះដូចដែលជនជាប់ចោទ នួន ជា និង អៀង សារី ធ្លាប់បានធ្វើ ។ នៅក្នុងសេចក្តីថ្លែងការណ៍របស់ខ្លួនជនជាប់ចោទ ខៀវ សំផន បានធ្វើការរៀបរាប់ដោយសម្តីមួយៗ និងខ្លាំងៗ ហើយបានចំណាយពេលប្រមាណ



ខៀវ សំផន ថ្លែងសុន្ទរកថាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ប្រភព ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

៤៥ នាទីដើម្បីអានដោយផ្តោតជាសំខាន់ទៅលើសេចក្តីថ្លែងបើកចោទប្រកាន់របស់សហព្រះរាជអាជ្ញាមកលើខ្លួន ។ ជនជាប់ចោទរូបនេះបានអះអាងថា ខ្លួនមិនបានដឹងពីបទល្មើសដែលបានប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យឡើយ និងថានៅក្នុងរបបនោះខ្លួនមិនមានសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចអ្វីទាំងអស់ ។

នៅពេលចាប់ផ្តើមជនជាប់ចោទ ខៀវ សំផន បានលើកឡើងថាខ្លួនមិនសូវយល់ដឹងអំពីនីតិវិធីរបស់តុលាការកាត់ទោសមកលើរូបខ្លួននោះទេ ព្រោះថាតុលាការនេះរៀបចំអ្វីៗគឺសម្រាប់តែសម្រួលដល់កិច្ចការរបស់ខ្លួនតែប៉ុណ្ណោះ ។ រីឯការចោទប្រកាន់របស់សហព្រះរាជអាជ្ញាគឺគ្រាន់តែធ្វើឡើងដោយស្មានៗ និងមិនមានភ័ស្តុតាងច្បាស់លាស់ដើម្បីបញ្ជាក់ឡើយ ។ ជនជាប់ចោទ ខៀវ សំផន បានសម្តែងពីភាពមិនពេញចិត្តរបស់ខ្លួនចំពោះសេចក្តីសន្និដ្ឋានចោទប្រកាន់របស់សហព្រះរាជអាជ្ញា ទាំងព្រះរាជអាជ្ញាជាតិនិងព្រះរាជអាជ្ញាអន្តរជាតិដោយបាននិយាយថា សេចក្តីសន្និដ្ឋានចោទប្រកាន់របស់សហព្រះរាជអាជ្ញាភាគច្រើនសម្អាងតែទៅលើសម្តីរបស់សាក្សីអនាមិក អត្ថបទដកស្រង់ចេញពីសៀវភៅ និងអត្ថបទដកស្រង់ចេញពីកាសែត ។ ជនជាប់ចោទ ខៀវ សំផន បានបន្តថា «បើតាមខ្ញុំដឹង អ្នកប្រវត្តិសាស្ត្រក្តី អ្នកកាសែតក្តី អ្នកចងក្រងរឿងសម្រាប់អ្នកកាសែតក្តី ឬក៏អ្នកប្រលោមលោកក្តី មិនមែនជាចៅក្រមទេ គ្មាននរណាម្នាក់ក្នុងចំណោមពួកគេបានស្បថធ្វើជាចៅក្រមស៊ើបអង្កេតសម្រាប់ដាក់បន្ទុក ឬដោះបន្ទុកកុំឲ្យលម្អៀងក្នុងមតិរបស់ពួកគេសោះទេ» ។ ជនជាប់ចោទ ខៀវ សំផន បានបន្តទៀតថា អ្នកសរសេរអត្ថបទ និងសៀវភៅទាំងអស់នោះមិនមានជាប់ចំណងពាក្យសន្យាតាមផ្លូវច្បាប់នោះទេ ហើយអ្នកទាំងអស់នោះមានអាចសិទ្ធិភ័ន្តប្រឡំ មានសិទ្ធិសរសេរដោយលម្អៀង និងមានសិទ្ធិបញ្ចេញមតិតាមចិត្តដោយមិនចាំបាច់ពិចារណាលើចំណុចណាមួយនោះទេ ។ ជនជាប់ចោទ ខៀវ សំផន បានរំឭកទៅលោកស្រីសហព្រះរាជអាជ្ញាជាតិ ជា លាង ថា ៖

> «នៅក្រោយថ្ងៃរំដោះ១៧ ខែមេសា ឆ្នាំ១៩៧៥ មានកាសែតបារាំងមួយឈ្មោះ ឡឺម៉ុង(Le Monde) បានចុះផ្សាយអត្ថបទមួយដែលមានចំណងជើងថា «ក្រុងភ្នំពេញត្រូវបានរំដោះហើយ» ខ្ញុំជឿជាក់ថា លោកស្រីច្បាស់ជាទិទានខ្ញុំមិនតិចទេ ប្រសិនបើខ្ញុំឆ្លៀតឱកាសយកអត្ថបទនោះមកប្រើ» ។

បន្ទាប់ពីជនជាប់ចោទ ខៀវ សំផន ឆ្លើយតបទៅនឹងការលើកឡើងរបស់សហព្រះរាជអាជ្ញាជាតិ លោកស្រី ជា លាង រួចមក ជនជាប់ចោទរូបនេះបានរំឭកពីពាក្យសម្តីរបស់សហព្រះរាជអាជ្ញាអន្តរជាតិ លោក អេនឌ្រូ ខេលី ដែលបានចោទប្រកាន់មកលើរូបខ្លួនថា កាលពីពេលដែលនៅជានិស្សិតខ្លួនបានចូលរួមក្នុងការប្រជុំជាច្រើនជាមួយនិស្សិតកុម្មុយនីស្ត នៅទីក្រុងប៉ារីស ដែលជាសញ្ញានៃការចាប់ផ្តើមនៃមហាឧក្រិដ្ឋកម្មរួមជាមួយនឹងអ្នកជាប់ចោទជាមួយខ្លួន ។ នៅត្រង់ចំណុចនេះជនជាប់ចោទ ខៀវ សំផន បានបញ្ជាក់ទៅលោកសហព្រះរាជអាជ្ញាអន្តរជាតិថា កាលពីពេលនៅទីក្រុងប៉ារីស ខ្លួនក៏បានរៀនសូត្រនិងបានបញ្ចប់និក្ខេបបទថ្នាក់បណ្ឌិតផ្នែកសេដ្ឋកិច្ចរបស់ខ្លួនយ៉ាងជោគជ័យ ជាការពិតខ្លួនក៏បានចាប់អារម្មណ៍ពីលទ្ធិកុម្មុយនីស្ត ហើយខ្លួនក៏បានសិក្សាពីអ្នកទ្រឹស្តីលទ្ធិកុម្មុយនីស្តដែរ ដោយសារនាពេលនេះកុម្មុយនីស្តគឺជាចលនាមួយដែលផ្តល់សេចក្តីសង្ឃឹមដល់យុវជនរាប់លាននាក់នៅលើសាកលលោកទាំងមូល ហើយអ្វីដែលខ្លួនចង់បាននាពេលនោះគឺជាអ្វីដែលជាបទពិសោធល្អសម្រាប់ប្រទេសកម្ពុជា ។ ជនជាប់ចោទរូបនេះក៏បានអះអាងថា ការចូលរួមក្នុងចលនាការកុម្មុយនីស្តនេះគឺជាមធ្យោបាយតែមួយគត់ដើម្បីជួយសង្គ្រោះប្រទេសកម្ពុជាចេញពីការគ្រប់គ្រង និងត្រួតត្រារបស់ពួកបរទេស ដោយរំឭកពីការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកមកលើប្រទេសកម្ពុជានៅចន្លោះខែមករា ឆ្នាំ១៩៧០ និងខែសីហា ឆ្នាំ១៩៧៣ ដែលមានចំនួនច្រើនជាងការទម្លាក់គ្រាប់បែករបស់ក្រុមប្រទេសសម្ព័ន្ធមិត្តនៅក្នុងសង្គ្រាមលោកលើកទី២ និងការទម្លាក់គ្រាប់បែកនៅទីក្រុងហ៊ីរ៉ូស៊ីម៉ា និងទីក្រុងណាហ្គាសាគីទៅទៀត ។ ជនជាប់ចោទ ខៀវ សំផន បានលើកជាសំណួរទៅកាន់សហព្រះរាជអាជ្ញាអន្តរជាតិថា

> «សូមលោកអញ្ជើញគិតមើលទៅមើលថាតើប្រទេសខ្ញុំទៅជាយ៉ាងណាក្រោយពីការសម្លាប់រង្គាលយ៉ាងនេះ សូមអស់លោកជួយគិតមើលចុះ តើប្រជាជនកម្ពុជា និងប្រទេសកម្ពុជាស្ថិតនៅក្នុងសភាពបែបណានៅពេលមានការទម្លាក់គ្រាប់បែក

យ៉ាងនេះ? អត់ទេ ឃើញថាលោកមិនព្រមគិតអំពីបញ្ហានេះទេ ចំពោះលោកឃើញថាលោកចូលចិត្តនិយាយរឿងពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ជាងដោយបំភ្លេច ឬដោយកែក្រឡៃប្រវត្តិសាស្ត្រនៅរយៈកាលនោះទៅវិញ។ ទោះលោកពេញចិត្ត ឬមិនពេញចិត្តក៏ដោយប្រជាជនភាគច្រើនបានគាំទ្រចលនាតស៊ូប្រឆាំងនឹងរបប លន់ នល់។ ទោះជាលោកពេញចិត្ត ឬមិនពេញចិត្តក៏ដោយ គឺជាចលនាប្រឆាំងនឹងការជិះជាន់នៅពេលរដ្ឋប្រហាររបស់លោក លន់ នល់ នៅឆ្នាំ១៩៧០ ហើយនៅខណៈដែលភ្លើងសង្គ្រាមវៀតណាមចូលមកដល់ប្រទេសកម្ពុជា។ គឺរូបខ្ញុំអ្នកជាទទួលបន្ទុកទាក់ទងរវាងសម្តេចសីហនុ និងអ្នកតស៊ូនៅក្នុងប្រទេស ក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាតើនេះជាឧក្រិដ្ឋកម្មឬ?

ជនជាប់ចោទ ខៀវ សំផន បានបន្តឆ្លើយតបទៅនឹងការចោទប្រកាន់របស់លោកសហព្រះរាជអាជ្ញាអន្តរជាតិ ខេលី ទៀតថា៖

«គេបានចោទប្រកាន់ខ្ញុំថាបានជួយ ប៉ុល ពត ឲ្យមកកាន់អំណាច ប៉ុន្តែខ្លួនខ្ញុំវិញ ខ្ញុំដឹងច្បាស់ថា ខ្ញុំបានរួមចំណែកឲ្យមានការរួបរួមកម្លាំងជាតិដើម្បីការពារមាតុភូមិរបស់ខ្ញុំ ដោយប្រាថ្នាចង់រស់នៅជាប្រជាជាតិមួយដែលអធិបតេយ្យ ឯករាជ្យ ទាំងចំពោះសហរដ្ឋអាមេរិក ទាំងចំពោះវៀតណាមកុម្មុយនីស្តដែលតែងតែរកគ្រប់មធ្យោបាយដើម្បីបញ្ចូលប្រទេសខ្ញុំឲ្យចូលទៅក្នុងសហព័ន្ធឥណ្ឌូចិនក្រោមការគ្រប់គ្រងរបស់វៀតណាម។ នៅក្នុងស្ថានការណ៍បែបនេះ ម្តេចក៏លោកហ៊ានអះអាងថា ខ្ញុំមានគំនិតចង់បំផ្លាញប្រជាជនកម្ពុជាដែលខ្ញុំស្រឡាញ់ជាងអ្វីៗទាំងអស់ ហើយដែលខ្ញុំខិតខំការពារមួយជីវិតខ្ញុំមកហើយនេះ?»

ជនជាប់ចោទ ខៀវ សំផន បានលើកឡើងថា អ្វីដែលសហព្រះរាជអាជ្ញាបានចោទប្រកាន់មកលើរូបខ្លួនក្នុងរយៈពេលពីរថ្ងៃកន្លងមកគឺមានការលម្អៀងខ្លាំងណាស់ ដែលធ្វើឲ្យខ្លួនមានអារម្មណ៍ថាសហព្រះរាជអាជ្ញាទាំងពីររូបគឺគ្រាន់តែធ្វើយ៉ាងណាចង់យកក្បាលរបស់ខ្លួនឲ្យខានតែបានប៉ុណ្ណោះ។ ខៀវ សំផន បានបន្តថាអ្វីដែលធ្វើឲ្យខ្លួនមានការធូរស្បើយក្នុងចិត្តក្រោយពីការស្តាប់ការលើកឡើងរបស់សហព្រះរាជអាជ្ញាអន្តរជាតិលោក ខេលី នោះគឺការទទួលស្គាល់របស់លោកដែលថា មុនថ្ងៃរំដោះភ្នំពេញ ថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ទីក្រុងនេះស្ថិតក្នុងសភាពដែលអាចក្លាយទៅជាមហន្តរាយដ៏ធំធេងដល់អាយុជីវិតរួចទៅហើយ គឺការខ្វះខាតនូវថ្នាំសង្កូវ និងម្ហូបអាហារដើម្បីបរិភោគ។ ប្រជាជនភាគច្រើនបានមកជ្រកកោននៅទីក្រុងដើម្បីរត់គេចពីការទម្លាក់គ្រាប់បែករបស់អាមេរិក ដោយសង្ឃឹមថានឹងទទួលបានការការពារ។ ជនជាប់ចោទរូបនេះបានបញ្ជាក់ប្រាប់ទៅលោកសហព្រះរាជអាជ្ញាអន្តរជាតិថា ក្រោយពីការទទួលស្គាល់របស់លោកសហព្រះរាជអាជ្ញាពីស្ថានភាពអាក្រក់ដែលកើតមានរួចជាស្រេចមុនពេលដែលខ្លួនមកដល់ទីក្រុងភ្នំពេញ ខ្លួននឹងនៅតែមានសេចក្តីសង្ឃឹមតិចតួចនៅក្នុងចិត្តថា លោកសហព្រះរាជអាជ្ញាអន្តរជាតិពិតជាមិនហ៊ានបន្តចោទប្រកាន់មកលើរូបខ្លួនទាក់ទងនឹងការជម្លៀសប្រជាជនចេញពីទីក្រុងទៀតឡើយ។ ប៉ុន្តែជនជាប់ចោទ ខៀវ សំផន បានសង្កត់ធ្ងន់ថា៖

«សេចក្តីសង្ឃឹមរបស់ខ្ញុំបានតែមួយភ្លែតប៉ុណ្ណោះ លោកក៏ចាប់ផ្តើមនិយាយពីសំណុំរឿងរាប់រយទំព័រហាក់បីដូចជាចំនួនទំព័រទាំងអស់នោះវាជាភស្តុតាងដូច្នោះដែរ។ ម្យ៉ាងទៀត គួរតែទាំងអស់គ្នាមានលទ្ធភាពអានឯកសាររាប់រយទំព័រនោះ តែឯកសារចំនួនរាប់ពាន់ទំព័រមិនទាន់បានបកប្រែ ទោះជាភាសាអង់គ្លេសក្តី ភាសាបារាំងក្តី គឺគ្មានបកប្រែជាភាសាទាំងពីរនោះទេ។ តើលោកផ្ទាល់ខ្លួនលោកបានអានឯកសារទាំងអស់ហើយឬនៅ? ខ្ញុំពិបាកជឿថាលោកបានអានណាស់។ ប្រសិនជាលោកបានអានអស់មែន តើលោកនៅតែអះអាងថាខ្ញុំជាសមាជិកអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា ក្នុងខណៈដែល

*គ្មានឯកសារណាមួយទាល់តែសោះបញ្ជាក់ថាខ្ញុំជាសមាជិកគណៈអចិន្ត្រៃយ៍ ។ ហើយក្នុងខណៈដែលអស់លោកមានតែកំណត់ហេតុតែ១៩សម្រាប់អង្គប្រជុំដែលមានចំនួនសរុប១៥០ទៅ២០០លើកដែលបានប្រព្រឹត្តទៅពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ។ បើស្រិនជាលោកបានអានសំណុំរឿង តើលោកនៅតែហ៊ានអះអាងថា នៅក្នុងចំនួនឯកសារទាំងនោះច្បាស់ជាមានភ័ស្តុតាងគាំទ្រការចោទប្រកាន់របស់លោកឬទេ? ក្នុងខណៈដែលនៅក្នុងចំណោមអង្គប្រជុំទាំង១៩លើក ដែលអស់លោកមានភ័ស្តុតាងជាឯកសារថាខ្ញុំបានចូលរួមក្នុងអង្គប្រជុំ១៩លើកមែន ។ តែខ្ញុំបាននិយាយតែពីរដង គឺនិយាយតែពីប្រធានបទដែលស្ថិតនៅក្នុងរង្វង់សមត្ថកិច្ចរបស់ខ្ញុំ មិនជាប់ទាក់ទងអ្វីទាល់តែសោះទៅនឹងរឿងឧក្រិដ្ឋកម្មដែលអស់លោកចោទប្រកាន់លើរូបខ្ញុំ ។ លោកសហព្រះរាជអាជ្ញា ហេតុអ្វីក៏គ្មានភ័ស្តុតាងបញ្ជាក់ថាខ្ញុំជាសមាជិកអចិន្ត្រៃជាផ្លូវការ? ហេតុអ្វីក៏គ្មានឯកសារណាមួយដែលបញ្ជាក់ថាខ្ញុំជាប្រធានមន្ទីរនយោបាយ៨៧០? វាគ្មានអ្វីក្រៅពីខ្ញុំមិនមែនជាសមាជិកគណៈអចិន្ត្រៃយ៍ ក្រៅពីខ្ញុំមិនមែនជាប្រធានមន្ទីរនយោបាយ៨៧០នោះទេ ។ នេះជាការពិត ទោះជាវាមិនស្របនឹងការស្មានរបស់លោកក៏ដោយ ។»*

ជនជាប់ចោទ ខៀវ សំផន បានបង្ហាញពីសេចក្ដីព្រួយបារម្ភរបស់ខ្លួនដោយលើកឡើងថា នៅពេលអានដីកាសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញានៅក្នុងថ្ងៃទីពីរនៃសវនាការខ្លួនបានកត់សម្គាល់ឃើញថា លោកសហព្រះរាជអាជ្ញាអន្តរជាតិ ខេលី បានប្រឌិតពាក្យថា «*កន្លែងមជ្ឈិមនៃបក្ស*» ដើម្បីគេចមិនព្រមបែងចែកឲ្យច្បាស់រវាងគណៈមជ្ឈិមបក្ស និងគណៈអចិន្ត្រៃយ៍ ដោយសារវាជាការរំខានដល់ការចោទប្រកាន់របស់លោកសហព្រះរាជអាជ្ញា ។ ជនជាប់ចោទរូបនេះបានចោទប្រកាន់ទៅលោកសហព្រះរាជអាជ្ញាអន្តរជាតិថា បានភូតកុហក និងបំភ្លៃការពិត ដោយចង់ធ្វើឲ្យសាធារណៈជនជឿថា មនុស្សទាំងអស់គ្នាសុទ្ធតែជាត្រីដែលនៅក្នុងកន្ត្រកតែមួយ ។ ជនជាប់ចោទ ខៀវ សំផន បានបញ្ជាក់ទៅសហព្រះរាជអាជ្ញាថា ៖

*«លោកដឹងច្បាស់ហើយថា កម្ពុជាប្រជាធិបតេយ្យមានរចនាសម្ព័ន្ធមួយដែលបែងចែកជាផ្នែកតូចៗដាច់ដោយឡែកពីគ្នា ហើយមានលាក់ការណ៍សម្ងាត់ខ្ពស់ណាស់ ។ លោកព្រះរាជអាជ្ញា លោកបានថ្លែងថាការណ៍ដែលខ្ញុំត្រូវបានតែងតាំងជាគណៈប្រធានរដ្ឋនោះ នាំឲ្យខ្ញុំស្ថិតនៅសហឧក្រិដ្ឋកម្មរួម ។ បើអ៊ីចឹង ហេតុដូចម្ដេចក៏លោកមិនធ្វើការចោទប្រកាន់លើព្រះមហាវីរក្សត្រ នរោត្តម សីហនុ ដែរទៅ? លោកដឹងច្បាស់ថា គណៈប្រធានរដ្ឋគ្រាន់តែជារបស់មួយដែលគេតាំងឲ្យល្អមើលតែប៉ុណ្ណោះគ្មានអ្វីពិតប្រាកដនោះទេ រហូតទាល់តែមិនដែលមានកិច្ចប្រជុំលើកណាសោះ ។ បើអ៊ីចឹងតើគេអាចប្រព្រឹត្តឧក្រិដ្ឋកម្មអ្វីបានទៅ បើគ្មានរូបគ្មានរាងយ៉ាងនេះ ។»*

ទាក់ទងការនឹងការចោទប្រកាន់របស់សហព្រះរាជអាជ្ញាចំពោះការដឹងឮអំពីស្ថានភាពរបស់ប្រជាជននៅតាមការដ្ឋានលើកទំនប់ដីកប្រឡាយនៅពេលដែលជនជាប់ចោទ ខៀវ សំផន ចុះធ្វើដំណើរ ទស្សនកិច្ចនៅតាមការដ្ឋាននោះ ជនជាប់ចោទ ខៀវ សំផន បានឆ្លើយតបទៅវិញ ដោយបានចោទជាសំណួរថា ៖

*តើលោកព្រះរាជអាជ្ញាផ្ទាល់ខ្លួនលោកច្បាស់ជាជឿអ៊ីចឹងមែនឬ? នៅពេលដែលខ្ញុំដង្ហែដំណើរព្រះករុណាទៅមើលការដ្ឋាននោះ ស្រាប់តែគេសម្លាប់ប្រជាជននឹងត្បងចប ឬបាញ់សម្លាប់នៅចំពោះមុខយើងទាំងអស់គ្នាយ៉ាងនេះ?»*

ជនជាប់ចោទ ខៀវ សំផន បានបដិសេធចំពោះការចោទប្រកាន់របស់សហព្រះរាជអាជ្ញាជាតិ លោកស្រី ជា លាង ទាក់ទងនឹងការបង្ខំឲ្យអាពាហ៍ពិពាហ៍ និងធ្វើយ៉ាងណាតាមដានមនុស្សម្នាក់ៗថាបានរួមដំណេកជាមួយគ្នាឬក៏អត់ ។ ដោយអះអាងថា ៖

*«ពិតណាស់ខ្ញុំមិនមែនជាសមាជិកអង្គការទេ តែខ្ញុំស្មានដឹងថា ក្នុងការគ្រប់គ្រងប្រទេសមួយទាំងមូល*

*សមាជិកអង្គការមានកិច្ចការផ្សេងទៀតច្រើនណាស់ដែលត្រូវធ្វើ មិនមានពេលឯណាមកតាមដានមើលការផ្សងដំណេករបស់ប្រជាជនឡើយ ។"*

ជនជាប់ចោទ ខៀវ សំផន បានបន្តទៀតថា សហចៅក្រមស៊ើបអង្កេត និងកាសែតមួយចំនួនបានបន្ទោសខ្លួនថា បាននិយាយប្រែប្រួលផ្លាស់ប្តូរក្នុងសេចក្តីប្រកាស និងក្នុងសៀវភៅដែលខ្លួនបានសរសេរ ។ ហើយជនជាប់ចោទ ខៀវ សំផន ខ្លួនឯងផ្ទាល់ក៏បានទទួលស្គាល់ពីការប្រែប្រួលនេះ ដោយបាននិយាយថា ខ្លួនជាការពិតខ្ញុំមានការវិវត្តមែន តែការវិវត្តនេះកើតមានបន្តិចម្តងៗ នៅពេលដែលខ្លួនបានដឹង និងបានគិតពិចារណាពីសម័យនៃប្រវត្តិសាស្ត្រកម្ពុជា ។ ប៉ុន្តែជនជាប់ចោទរូបនេះបានលើកជាសំណួរថា "*តើគេអាចយកដំណើរការនៃការគិតពិចារណារបស់ខ្ញុំនេះមកប្រឆាំងនឹងរូបខ្ញុំដែរឬទេ?*" និងបញ្ជាក់ថា មេធាវីរបស់ខ្លួនបានស្នើឲ្យថា គួរតែកម្រិតការនិយាយតែត្រឹមព្រឹត្តការណ៍ដែលខ្លួនបានឃើញនិងបានដឹងនៅក្នុងសម័យនោះ ។ ប៉ុន្តែជនជាប់ចោទរូបនេះបញ្ជាក់ថា វាគឺជារឿងមួយដែលពិបាកនឹងធ្វើ ដោយសារមនុស្សម្នាក់ៗក្នុងរយៈពេល៣៦ឆ្នាំ ប្រាកដជាត្រូវការចង់យល់ចង់ដឹង និងចេះតែវិវត្តប្រែប្រួល ។

ជនជាប់ចោទ ខៀវ សំផន បានលើកឡើងថា ខ្លួនសង្ឃឹមថាសវនាការនេះគឺអាចជាឱកាសល្អមួយសម្រាប់ឲ្យខ្លួនបានពន្យល់ដល់ប្រជាជនកម្ពុជាឲ្យយល់ថាហេតុម្តេចបានជាខ្លួនដែលជាអ្នកកាន់តំណែងមួយខ្ពស់ជាដូវការក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយនៅតែថាមិនដែលបានចូលរួមសម្រេចកិច្ចការអ្វីធំដុំ និងមិនបានដឹងអំពីអ្វីដែលបានកើតមាននៅក្នុងប្រទេសកម្ពុជានៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យនោះ ។ មុននឹងបញ្ចប់ជនជាប់ចោទ ខៀវ សំផន បានបង្ហាញពីការសន្យារបស់ខ្លួនថា ៖

*"ខ្ញុំបានសន្យាជាមួយបងប្អូនជនរួមជាតិហើយថាខ្ញុំនឹងព្យាយាមគោរពតាមពាក្យសន្យានោះ ។ នេះជាការងារមួយលំបាកសម្រាប់ខ្ញុំ តែខ្ញុំមានជំនឿជឿជាក់ថា ដំណើរការតុលាការកាន់តែឈានទៅមុខជាបណ្តើរៗទៅ ព្រះសង្ឃ និងបងប្អូនជនរួមជាតិនឹងឃើញនិងអាចវិនិច្ឆ័យបានដោយខ្លួនឯងផ្ទាល់" ។*

### ឃ) ការឆ្លើយតបរបស់មេធាវីការពារក្តី ខៀវ សំផន

ក្រោយពេលជនជាប់ចោទ ខៀវ សំផន បញ្ចប់ការអានសេចក្តីថ្លែងការណ៍របស់ខ្លួន ប្រធានអង្គជំនុំជម្រះលោកចៅក្រម និល ណុន បានផ្តល់ឱកាសឲ្យសហមេធាវីជាតិការពារក្តីរបស់ជនជាប់ចោទ ខៀវ សំផន គឺលោក គង់ សំអុន ឡើងធ្វើសេចក្តីឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានចោទប្រកាន់របស់សហព្រះរាជអាជ្ញា ។ នៅក្នុងអំណះអំណាងរបស់ខ្លួន លោកមេធាវី គង់ សំអុន បានឆ្លើយតបស៊ើររាល់គ្រប់ចំណុចទាំងអស់ដែលសហព្រះរាជអាជ្ញាបានធ្វើការសន្និដ្ឋានចោទប្រកាន់មកលើកូនក្តីរបស់ខ្លួន ។ លោកមេធាវីបានលើកឡើងថា សហព្រះរាជអាជ្ញាបានសម្អាងទៅលើអង្គហេតុដែលកន្លងផុតអស់រយៈពេលជាយូរមកហើយ និងពឹងផ្អែកទៅលើភ័ស្តុតាង និងឯកសារចាស់ៗដូចជាសៀវភៅឯកសារ និងសារព័ត៌មានដែលសរសេរ ឬនិពន្ធឡើងនៅក្រោយព្រឹត្តការណ៍កើតឡើងតែប៉ុណ្ណោះ ។ លោកមេធាវី សំអុន បានធ្វើការប្រៀបធៀបសវនាការដែលរៀបចំឡើងដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមនាពេលនេះទៅនឹងសវនាការ ដែលធ្វើឡើងរវាងមនោគមវិជ្ជាកុម្មុយនីស្តនិងមនោគមវិជ្ជារបស់ក្រុមប្រទេសលោកសេរី ដោយសារតែតុលាការនេះត្រូវបានបង្កើតឡើងដោយក្រុមប្រទេសដែលមានមនោគមវិជ្ជាសេរី ហើយកំពុងតែកាត់ទោសទៅលើក្រុមមេដឹកនាំខ្មែរក្រហមដែលប្រកាន់និន្នាការកុម្មុយនីស្ត ។ លោកមេធាវី សំអុន បានបន្ថែមថា នៅអំឡុងពេលនៃការចូលកាន់អំណាចរបស់របបកម្ពុជាប្រជាធិបតេយ្យ គឺជារឿងធម្មតាទេដែលកើតមានអំពើហិង្សាផ្នែកនយោបាយនិងការកំណត់ថាអ្នកណាដែលត្រូវធ្វើជាស្តេច និងនរណាដែលត្រូវសម្លាប់ ឬចាប់ខ្លួន ដោយសារតែការដណ្តើមចូលកាន់អំណាចនេះគឺធ្វើឡើងដោយប្រើសង្គ្រាមមិនមែនដណ្តើមអំណាចដោយប្រជាធិបតេយ្យឡើយ ។ លោកមេធាវី សំអុន ក៏បានផ្តើមធ្វើការរៀបរាប់ពីប្រវត្តិនៃការសិក្សារបស់ជនជាប់ចោទ ខៀវ សំផន ជូនទៅអង្គជំនុំជម្រះដើម្បីបង្ហាញថាកូនក្តីរបស់ខ្លួនគឺជាអ្នកដែលមានចំណេះដឹង និងជាអ្នកស្នេហាជាតិដោយធ្លាប់បានទៅសិក្សានៅប្រទេសបារាំង និងបានទទួលសញ្ញាប័ត្រថ្នាក់បណ្ឌិតផ្នែកសេដ្ឋកិច្ច ហើយក្រោយមកត្រូវបានជាប់ឆ្នោតជាតំណាងរាស្ត្រ និងត្រូវបានតែងតាំងដោយសម្តេច នរោត្តម

សីហនុ ជារដ្ឋលេខាធិការដែលជាតួនាទីមួយខ្ពស់នាសម័យសង្គមរាស្ត្រនិយម ។ លោកមេធាវី សំអុន បានបញ្ជាក់ថា ការចូលរួមនៅក្នុងចលនារំដោះជាតិជាមួយក្រុមខ្មែរក្រហមរបស់ជនជាប់ចោទ ខៀវ សំផន មិនមែនដើម្បីបំផ្លាញជាតិនោះទេ តែដោយសារការចោទប្រកាន់ពីសំណាក់រដ្ឋាភិបាលរបស់សម្តេច សីហនុ ថា ខៀវ សំផន ជាអ្នកឆ្វេងនិយម ហើយក៏នាំឲ្យមានរត់ចូលក្នុងព្រៃដោយសារការព្រួយបារម្ភពីសុវត្ថិភាព ។ លោកមេធាវី សំអុន បានបន្ទោសទៅលើផ្នែកកិច្ចការសាធារណៈរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលបានផ្សព្វផ្សាយព័ត៌មានខុសទាក់ទងនឹងឆ្នាំដែលជនជាប់ ចោទ ខៀវ សំផនចូលកាន់មុខតំណែងជាប្រមុខរដ្ឋដោយសារផ្នែកកិច្ចការសាធារណៈបានផ្សព្វផ្សាយនៅក្នុងព័ត៌មានរបស់ខ្លួនថាជនជាប់ចោទ ខៀវ សំផន ត្រូវបានតែងតាំងជាប្រមុខរដ្ឋនៅក្នុងឆ្នាំ១៩៧៥ ប៉ុន្តែជាក់ស្តែងជនជាប់ចោទ ខៀវ សំផន ត្រូវបានតែងតាំងនៅក្នុងឆ្នាំ១៩៧៦ គឺនៅក្រោយការលាឈប់ពីតំណែងជាប្រមុខរដ្ឋរបស់សម្តេច នរោត្តម សីហនុ ។ លោកមេធាវី សំអុន បានបន្តចោទជាសំណួរថា បើតុលាការចោទប្រកាន់ជនជាប់ចោទ ខៀវ សំផន ថា ធ្លាប់មានតំណែងជាប្រមុខរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យដែលត្រូវទទួលខុសត្រូវចំពោះអំពើទាំងឡាយដែលកើតឡើងនៅពេលនោះ ហេតុអ្វីក៏តុលាការមិនព្រមយាងសម្តេច សីហនុ មកកាត់ទោសនៅចំពោះមុខតុលាការនេះដែរទៅ? ដោយសារទ្រង់ក៏ធ្លាប់ជាអតីតប្រមុខរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យដូចគ្នានឹងជនជាប់ចោទ ខៀវ សំផន ដែរ ។ ប៉ុន្តែលោកមេធាវី សំអុន ជឿជាក់ថា តុលាការនេះមិនអាចយាងទ្រង់ឲ្យចូលមកបំភ្លឺនៅក្នុងតុលាការនេះបានទេ ប៉ុន្តែតុលាការអាចប្រើប្រាស់សៀវភៅដែលព្រះអង្គបាននិពន្ធដោយផ្ទាល់ និងរៀបរាប់ពីជីវប្រវត្តិរបស់ទ្រង់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលបញ្ជាក់ថានៅក្នុងពេលដែលទ្រង់កាន់តំណែងជាព្រះប្រមុខរដ្ឋនៅអំឡុងពេលនៃរបបខ្មែរក្រហម គឺទ្រង់មិនមានសិទ្ធិអំណាចក្នុងការសម្រេចអ្វីទាំងអស់ ដូច្នេះមានន័យថា កូនក្តីរបស់ខ្លួនគឺជនជាប់ចោទ ខៀវ សំផន ក៏មិនមានសិទ្ធិអំណាចអ្វីដែរ ។ ដោយលោកមេធាវីបានអះអាងថា ឋានៈជាប្រមុខរដ្ឋរបស់ ខៀវ សំផន គឺមិនមានការិយាល័យសម្រាប់ធ្វើការ មិនមានបុគ្គលិក គឺមានតែម្នាក់ឯងប៉ុណ្ណោះ ។ រីឯការលើកឡើងរបស់សហព្រះរាជអាជ្ញាដែលថាមន្ទីរ ម-៨៧០ ត្រូវបានគ្រប់គ្រងដោយ ខៀវ សំផន នៅក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យវិញ បាននាំឲ្យមានការយល់ច្រឡំចំពោះការងាររបស់កូនក្តីរបស់ខ្លួន ដោយលោកមេធាវី សំអុន បានបញ្ជាក់ថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យគេបានបែងចែកជាការិយាល័យពីរគឺគណៈ៨៧០ និងមន្ទីរ៨៧០ ហើយព្រះរាជអាជ្ញាមិនបានបង្ហាញឲ្យបានច្បាស់លាស់អំពីរឿងរាវទាំងអស់នេះទេ ។ លោកគង់ សំអុន បានបញ្ជាក់ថា គណៈ៨៧០ គឺជាកន្លែងតំណាងឲ្យគណៈអចិន្ត្រៃយ៍ ដែលគណៈអចិន្ត្រៃយ៍ជាអ្នកធ្វើប្រតិបត្តិការប្រចាំថ្ងៃដឹកនាំនយោបាយប្រចាំថ្ងៃនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ រីឯមន្ទីរម-៨៧០ គឺគ្រាន់តែជាមន្ទីរនយោបាយមួយដែលមានបុគ្គលម្នាក់ទទួលខុសត្រូវតាមដាន និងធ្វើការរាយការណ៍ ហើយជាចៃដន្យជនជាប់ចោទ ខៀវ សំផន បានអង្គុយធ្វើការជាមួយអ្នកទទួលខុសត្រូវនៅក្នុងមន្ទីរ ម-៨៧០នោះ ហេតុនេះវាបានធ្វើឲ្យមានការយល់ច្រឡំថាមន្ទីរនោះជាការិយាល័យរបស់ ខៀវ សំផន ។ ឆ្លើយតបទៅនឹងការលើកឡើងរបស់សហព្រះរាជអាជ្ញាដែលថាជនជាប់ចោទទាំងបីរូបរួមមាន ខៀវ សំផន នួន ជា និងអៀង សារី មិនមានបាតដៃប្រឡាក់ឈាម ប៉ុន្តែអ្នកទាំងនោះស្ថិតនៅក្នុងសមុទ្រឈាម លោកមេធាវី សំអុន បានលើកឡើងថា នេះគឺគ្រាន់តែជាការប្រើប្រាស់នូវវោហាសាស្ត្រ និងជាការលើកឡើងតាមរបៀបប្រលោមលោកដែលមិនជាប់ទាក់ទងនឹងទិដ្ឋភាពជាក់ស្តែង និងមិនស្ថិតក្នុងគោលការណ៍ច្បាប់ ។ ចំពោះការចោទប្រកាន់របស់សហព្រះរាជអាជ្ញាទាក់ទងនឹងការដាក់ប្រជាជនខ្មែរទាំងអស់ឲ្យទៅជាទាសករនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ លោកមេធាវី សំអុន អះអាងថាវាជារឿងដែលមិនអាចទទួលយកបានទេ ព្រោះថាជនជាប់ចោទ ខៀវ សំផន និង ប៉ុល ពត ក៏ជាជនជាតិខ្មែរ ហេតុដូច្នេះការលើកឡើងរបស់សហព្រះរាជអាជ្ញា គឺគ្រាន់តែជាការសន្មតមួយដែលមិនបានបង្ហាញពីចំនួនជាក់លាក់នៃជនរងគ្រោះដែលបានក្លាយខ្លួនទៅជាទាសករនៅអំឡុងពេលការកាន់អំណាចរបស់ក្រុមខ្មែរក្រហម ។ ទាក់ទងនឹងវត្តមានរបស់ជនជាប់ចោទ ខៀវ សំផន នៅក្នុងអង្គប្រជុំរបស់គណៈកម្មការអចិន្ត្រៃយ៍ចំនួន១៨ដងក្នុងចំណោម១៩ដងដែលសហព្រះរាជអាជ្ញាបានលើកឡើងដើម្បី

*ចោទប្រកាន់ទៅលើជនជាប់ចោទ ខៀវ សំផន ថាបានដឹងពីសេចក្តីសម្រេចនានារបស់គណៈអចិន្ត្រៃយ៍ លោកមេធាវី សំអុន បានស្នើសុំឲ្យអង្គជំនុំជម្រះយកចិត្តទុកដាក់ទៅលើកំណត់ហេតុដែលកត់ត្រាពីវត្តមានរបស់អ្នកចូលរួមឲ្យបានច្បាស់លាស់ថាតើកំណត់ហេតុទាំងនោះជាកំណត់ហេតុពិតប្រាកដ ឬក្លែងក្លាយ ដោយសារតែនៅក្នុងកំណត់ហេតុទាំងអស់នោះមិនមានការចុះហត្ថលេខាពីនរណាម្នាក់ឡើយ ដូច្នេះវាអាចនឹងត្រូវបានគេកែប្រែនៅពេលក្រោយបានគ្រប់ពេលវេលា ។ ទាក់ទងនឹងការយល់ដឹងច្បាស់ពីឧក្រិដ្ឋកម្មទាំងឡាយដែលចោទប្រកាន់ដោយសហព្រះរាជអាជ្ញា លោកមេធាវី សំអុន បានឆ្លើយតបថា សហព្រះរាជអាជ្ញាត្រូវតែបង្ហាញឲ្យលើសពីវិមតិសង្ស័យទាក់ទងនឹងការយល់ដឹងរបស់ជនជាប់ចោទ ខៀវ សំផន ចំពោះឧក្រិដ្ឋកម្មត្រូវបានចោទប្រកាន់ទាំងនោះ ដោយសារតែជនជាប់ចោទ ខៀវ សំផន ដឹងត្រឹមតែអ្វីដែលរបបនោះអនុញ្ញាតឲ្យដឹងតែប៉ុណ្ណោះ ។ លើសពីនេះ អ្នកដែលធ្វើការឲ្យរបបកម្ពុជាប្រជាធិបតេយ្យគឺគេផ្តោតការយកចិត្តទុកដាក់តែទៅលើការងាររបស់គេរៀងៗខ្លួនប៉ុណ្ណោះ ហេតុនេះគ្មាននរណាអាចដឹងពីការងាររបស់អ្នកដទៃបានឡើយ ។*

*លោកសហមេធាវី គង់ សំអុន បានធ្វើសេចក្តីសន្និដ្ឋានដោយលើកឡើងពីភាពចលាចល និងភាពគ្មានសណ្តាប់ធ្នាប់ដែលបណ្តាលមកពីការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកមកលើប្រទេសកម្ពុជា និងជម្លោះប្រដាប់អាវុធរវាងភាគីខ្មែរក្រហម និងកងទ័ពរបស់រដ្ឋាភិបាលសាធារណរដ្ឋខ្មែរដែលដឹកនាំដោយសេនាប្រមុខ លន់ ណល់ កើតឡើងនៅក្នុងទសវត្សរ៍ទី៧០ ដែលបណ្តាលឲ្យកើតមានការកាប់សម្លាប់ និងឧក្រិដ្ឋកម្មនានា ។ ម្យ៉ាងវិញទៀត ជ័យជម្នះរបស់របបកម្ពុជាប្រជាធិបតេយ្យគឺធ្វើឡើងដោយសារសង្គ្រាម មិនមែនដោយសារប្រជាធិបតេយ្យនោះទេ ហេតុនេះការកាប់សម្លាប់គ្នារវាងភាគីជម្លោះអាចនឹងងាយកើតមាន ។ មុននឹងបញ្ចប់សេចក្តីសន្និដ្ឋានរបស់ខ្លួន លោកមេធាវី គង់ សំអុន បានស្នើសុំទៅអង្គជំនុំជម្រះឲ្យពិនិត្យមើលដោយយកចិត្តទុកដាក់ទៅលើភស្តុតាង និងបញ្ជីឈ្មោះរបស់សាក្សីដើម្បីកុំឲ្យមានការប្រើប្រាស់ភស្តុតាងក្លែងក្លាយ និងមិនច្បាស់លាស់ ដូចជាចម្លើយសារភាពដែលមាននៅក្នុងមន្ទីរស-២១ជាដើម ។*

*បន្ទាប់ពីការសន្និដ្ឋានរបស់លោកមេធាវីជាតិ គង់ សំអុន សហមេធាវីការពារក្តីអន្តរជាតិរបស់លោក ខៀវ សំផន ម្នាក់ទៀត គឺលោក ហ្សាក់ វែរហ្សេ (Jaques VERGÉS) បានឡើងធ្វើសេចក្តី*



**មេធាវីអន្តរជាតិ ហ្សាក់ វែរហ្សេ (រូបថត ៖ អ.វ.ត.ក)**

*សន្និដ្ឋានឆ្លើយតបទៅនឹងការចោទប្រកាន់របស់សហព្រះរាជអាជ្ញា បន្ថែមពីលើសហភាគីរបស់ខ្លួនដោយអះអាងថា សហព្រះរាជអាជ្ញាមិនបានលើកឡើងពីការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកមកលើប្រទេសកម្ពុជា នៅអំឡុងទសវត្សទី៧០ ឡើយ ដែលការទម្លាក់គ្រាប់បែកនេះបានបន្សល់ទុកកុមារកំព្រារាប់ម៉ឺននាក់នៅកម្ពុជា ។ លោកមេធាវីបានបន្តថា សហព្រះរាជអាជ្ញាបានតែងរឿងប្រលោមលោកបានយ៉ាងល្អនៅក្នុងសេចក្តីថ្លែងបើកការចោទប្រកាន់របស់ខ្លួន ហើយនៅក្នុងប្រលោមលោកនោះគឺផ្អែកតែទៅលើរបាយការណ៍ អត្ថបទខ្លីៗរបស់អ្នកកាសែត និងអត្ថបទអនាមិក ដែលជាការបំប្លែងការពិតនៃប្រវត្តិសាស្ត្រទាំងស្រុង ដោយសហព្រះរាជអាជ្ញាគឺគ្រាន់តែចង់ធ្វើយ៉ាងណាត្រូវតែយកលោក ខៀវ សំផន មកកាត់ទោស ឲ្យខានតែបានតែប៉ុណ្ណោះ ។ ប៉ុន្តែលោកមេធាវី វែរហ្សេ ក៏បានទទួលស្គាល់ដែលថា មនុស្សគ្រប់រូបតែងតែមានកំហុស និងអាចប្រព្រឹត្តនូវឧក្រិដ្ឋកម្មផ្សេងៗ ប៉ុន្តែពួកគេមិនមែនជាបិសាចនោះទេ ហើយការដែលសហព្រះរាជអាជ្ញាចោទជនជាប់ចោទទាំងបីរូបថាជាបិសាច គឺជាការខុសឆ្គងមួយ ។ លោកមេធាវីបានអះអាងថា ជនជាប់ចោទ ខៀវ សំផន គ្មានអ្វីដែលត្រូវសូមអភ័យទោសឡើយ ។ លោកមេធាវី វែរហ្សេ បានបញ្ចប់ការសន្និដ្ឋានរបស់ខ្លួនជាមួយនឹងការលើកឡើងនូវពាក្យ*

សម្ដីមួយឃ្លារបស់ព្រះចៅអធិរាជ ណាប៉ូឡេអុងនៃប្រទេសបារាំង ដែលបាននិយាយថា «អ្វីៗទាំងឡាយដែលនិយាយលើសពីការពិត គឺជារឿងដែលឥតប្រយោជន៍» និងបានស្នើសុំទៅអង្គជំនុំជម្រះពិនិត្យមើលទៅលើសេចក្ដីថ្លែងការណ៍ដែលមានលក្ខណៈលើសពីការពិតរបស់សហព្រះរាជអាជ្ញាជាហេតុនាំឲ្យសេចក្ដីថ្លែងការណ៍ទាំងនោះក្លាយទៅជា រឿងឥតប្រយោជន៍ ។

## សន្និដ្ឋាន

ការចាប់ផ្ដើមសវនាការលើអង្គសេចក្ដីនៅក្នុងសំណុំរឿង ០០២ ដោយអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានាពេលនេះគឺជាអ្វីដែលប្រជាជនកម្ពុជាបានទន្ទឹងរង់ចាំអស់រយៈពេល៣២ឆ្នាំមកហើយ ដើម្បីទទួលបាននូវភាពយុត្តិធម៌ និងស្វែងរកនូវការពិតនៃរបបខ្មែរក្រហម ។ នៅក្នុងសវនាការទាំងបីថ្ងៃបានបង្ហាញពីសញ្ញាណវិជ្ជមាននៅក្នុងដំណើរនាំទៅរកការលាតត្រដាងពីការពិតទាំងឡាយដែលកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយនៅមុនពេលបញ្ចប់កិច្ចដំណើរការនៃសវនាការជនជាប់ចោទ ខៀវ សំផន និងជនជាប់ចោទ នួន ជា បានបង្ហាញពីចេតនារបស់ខ្លួនដើម្បីធ្វើការឆ្លើយតបទៅនឹងរាល់ចោទប្រកាន់ទាំងឡាយដែលធ្វើឡើងដោយសហព្រះរាជអាជ្ញាប្រឆាំងនឹងខ្លួន ។ ទោះបីជនជាប់ចោទ អៀង សារី ធ្លាប់បានបង្ហាញពីចេតនាក្នុងការប្រើប្រាស់សិទ្ធិមិនឆ្លើយតប ឬធ្វើសក្ខីកម្មនៅក្នុងសវនាការក៏ដោយក៏ជនជាប់ចោទរូបនេះបានលើកឡើងនៅក្នុងសវនាការថា ខ្លួននឹងនៅតែបន្តចូលរួមក្នុងនីតិវិធីរបស់តុលាការដោយចូលរួមស្ដាប់ការចោទប្រកាន់ទាំងឡាយដែលធ្វើឡើងប្រឆាំងមកលើខ្លួន ។ ក៏ប៉ុន្តែសម្រាប់សិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២នេះហាក់បីដូចជាកំពុងត្រូវបានរឹតបន្តឹងចំពោះសិទ្ធិក្នុងការចូលរួមនៅក្នុងសវនាការដោយអង្គជំនុំជម្រះ ។ អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានផ្ដល់ហេតុផលថាសំណុំរឿង០០២ ជាសំណុំរឿងដែលមានលក្ខណៈស្មុគស្មាញ ជនជាប់ចោទទាំងអស់សុទ្ធតែមានវ័យកាន់តែចាស់ជរា រីឯដើមបណ្ដឹងរដ្ឋប្បវេណីមានចំនួនច្រើនដែលតម្រូវឲ្យមានការពន្លឿនកិច្ចដំណើរការនីតិវិធី ហេតុនេះការស្នើសុំណាមួយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងដំណាក់កាលនេះនឹងពន្យឺតដំណើរការសវនាការ ។

ទោះជាយ៉ាងណា ការចាប់ផ្ដើមសវនាការលើអង្គសេចក្ដីនៅក្នុងសំណុំរឿង០០២នាពេលនេះ គឺជាការបោះជំហានឆ្ពោះទៅមុខយ៉ាងសំខាន់របស់តុលាការក្នុងការស្វែងរកយុត្តិធម៌ជូនប្រជាជនកម្ពុជា ។

## បញ្ហាផ្សេងៗ

### ◆ *សវនាការថ្ងៃទី១*

នៅអំឡុងពេលនៃការចាប់ផ្ដើមសវនាការលើអង្គសេចក្ដីមានការផ្លាស់ប្ដូរ និងមានការតែងតាំងមេធាវីថ្មីៗជាច្រើនរូបទាំងខាងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងទាំងខាងមេធាវីការពារក្ដីរបស់ជនជាប់ចោទ ។ សហមេធាវីជាតិការពារក្ដីរបស់ជនជាប់ចោទ ខៀវ សំផនគឺលោកមេធាវី ស សុវ៉ាន ត្រូវបានជំនួសដោយលោកមេធាវី គង់ សំអុន និងមានការស្នើសុំតែងតាំងមេធាវីបរទេសមួយរូបបន្ថែមទៀត ។ រីឯជនជាប់ចោទ នួន ជា បានស្នើសុំតែងតាំងមេធាវីបរទេសមួយរូបបន្ថែមទៀតគឺលោក អេនឌ្រូ អ៊ីណូហ្វី ។ ចំពោះខាងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី សហមេធាវីនាំមុខតំណាងរដ្ឋប្បវេណី បានស្នើសុំទៅអង្គជំនុំជម្រះឲ្យធ្វើការតែងតាំងមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីចំនួនបីរូបបន្ថែម ប៉ុន្តែដោយសារមានបញ្ហាបច្ចេកទេសផ្នែកសំឡេង ដែលបណ្ដាលឲ្យប្រធានអង្គជំនុំជម្រះលោក ចៅក្រម និល ណុន បានពន្យារពេលការប្រកាសទទួលស្គាល់មេធាវីទាំងបីរូបទៅថ្ងៃចុងក្រោយនៃសវនាការ ។

នៅមុនពេលការអានសេចក្ដីសន្និដ្ឋានចោទប្រកាន់របស់សហព្រះរាជអាជ្ញា សហមេធាវីអន្តរជាតិការពារក្ដីជនជាប់ចោទ នួន ជា គឺលោក ម៉ៃឃើល ផេស្ដមេន និងសហមេធាវីអន្តរជាតិការពារក្ដីជនជាប់ចោទ អៀង សារី គឺលោក ខាណាវ៉ាស បានស្នើសុំឲ្យលោកស្រីចៅក្រមអន្តរជាតិ ស៊ីលវៀ ខាតវ៉្រាយត៍ដកខ្លួនចេញពីសវនាការដោយសារតែលោកស្រីចៅក្រមមិនទាន់បានផ្ដល់នូវការបកស្រាយទាក់ទងនឹងជំនួបរវាងលោកស្រីជាមួយនឹងសហព្រះរាជអាជ្ញាអន្តរជាតិ លោក អេនឌ្រូ ខេលី និងអ្នកដទៃផ្សេងទៀត ។ ប៉ុន្តែសំណើនេះត្រូវលោកប្រធានអង្គជំនុំជម្រះ និល ណុន បានបដិសេធ និងសម្អាងថាអង្គជំនុំជម្រះនឹងផ្ដល់នូវការបកស្រាយចំពោះបញ្ហានេះនៅក្នុងពេលវេលាសមស្រប ។

ភ្លាមៗ ក្រោយពីសេចក្តីសម្រេចនេះ ជនជាប់ចោទ អៀង សារី បានស្នើសុំទៅអង្គជំនុំជម្រះឡើងធ្វើសេចក្តីថ្លែងការណ៍របស់ខ្លួន ប៉ុន្តែសំណើនេះត្រូវបានអង្គជំនុំជម្រះបដិសេធដោយមូលហេតុខុសពីរបៀបវារៈរបស់សវនាការ ។

នៅអំឡុងពេលនៃដំណើរការនីតិវិធី មេធាវីការពារក្តីរបស់ជនជាប់ចោទ អៀង សារី គឺលោក អាង ឧត្តម បានស្នើសុំទៅអង្គជំនុំជម្រះអនុញ្ញាតឲ្យកូនក្តីរបស់ខ្លួនចាកចេញពីបន្ទប់សវនាការ ហើយតាមដានកិច្ចដំណើរការ នីតិវិធីពីចម្ងាយតាមរយៈប្រព័ន្ធសោទស្សន៍នៅក្នុងបន្ទប់រង់ចាំ ។ សំណើនេះត្រូវបានច្រានចោលដោយអង្គជំនុំជម្រះផ្តល់ហេតុផលថាវត្តមានរបស់ជនជាប់ចោទនៅក្នុងសវនាការស្តីពីការបើកការចោទប្រកាន់លើជនជាប់ចោទនាពេលនេះ ជាកត្តាសំខាន់ដែលធានាថាជនជាប់ចោទ អៀង សារី បានស្តាប់យ៉ាងពេញលេញពីបទចោទដែលប្រឆាំងនឹងខ្លួន ។ នៅថ្ងៃបន្ទាប់មេធាវីការពារក្តីជនជាប់ ចោទ អៀង សារី លោកមេធាវី ខាណាវ៉ាស បានស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើ



មេធាវីអន្តរជាតិ ម៉ៃឃើល ខាណាវ៉ាស (រូបថត ៖ អ.វ.ត.ក)

ការពិចារណាឡើងវិញលើសេចក្តីសម្រេចបដិសេធលើសំណើរបស់ខ្លួន ។ លោកមេធាវីលើកឡើងថា ការបង្ខំឲ្យជនជាប់ចោទត្រូវមានវត្តមាននៅក្នុងសាលសវនាការទាំងជនជាប់ចោទមិនអាចផ្ចង់អារម្មណ៍ដើម្បីយល់ពីអ្វីដែលសហព្រះរាជអាជ្ញាកំពុងតែចោទប្រកាន់មកលើខ្លួន គឺជាការរំលោភលើសិទ្ធិរបស់ជនជាប់ចោទ ។ លោកមេធាវីបានបន្តថា ការអនុវត្តរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិមួយចំនួនដូចជា តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី សេរ៉ាឡេអូន រ៉្វាន់ដា ឡេបាណន់ មិនមានតុលាការណាមួយដែលបង្ខំឲ្យជនជាប់ចោទត្រូវតែមានវត្តមាននៅក្នុងសាលសវនាការនោះទេ ។ ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងនៅតែរក្សាសេចក្តីសម្រេចច្រានចោលសំណើសុំរបស់សហមេធាវីការពារក្តីជនជាប់ចោទ អៀង សារី ដោយសម្អាងទៅលើហេតុផលដូចដែលខ្លួនធ្លាប់បានផ្តល់រួចមកហើយ ។

**◆ សវនាការថ្ងៃទី២**

នៅក្រោយពេលសហព្រះរាជអាជ្ញាបានបញ្ចប់សេចក្តីថ្លែងសន្និដ្ឋានចោទប្រកាន់លើជនជាប់ចោទទាំងបីរូបនៅអំឡុងសវនាការនាពេលរសៀល អង្គជំនុំជម្រះបានផ្តល់ឱកាសដល់សហមេធាវីការពារក្តីរបស់ជនជាប់ចោទ នួន ជា ធ្វើសេចក្តីសន្និដ្ឋានឆ្លើយតបទៅនឹងការចោទប្រកាន់របស់សហព្រះរាជអាជ្ញាដែលធ្វើឡើងរយៈពេលមួយថ្ងៃកន្លះកន្លងមក ។ ប៉ុន្តែសហមេធាវីអន្តរជាតិ លោក ម៉ៃឃើល ផេស្តម៉ែន បានស្នើសុំទៅអង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ធ្វើសេចក្តីថ្លែងការណ៍មុន ហើយខ្លួននឹងធ្វើការឆ្លើយតបទៅនឹងការសន្និដ្ឋានចោទប្រកាន់របស់សហព្រះរាជអាជ្ញានៅថ្ងៃបន្ទាប់ ។ មេធាវីរូបនេះបានបញ្ជាក់ថា ខ្លួនមានការលំបាកក្នុងការឆ្លើយតបទៅនឹងការចោទប្រកាន់មកលើកូនក្តីរបស់ខ្លួន ដោយមូលហេតុថា សេចក្តីសន្និដ្ឋានចោទប្រកាន់របស់សហព្រះរាជអាជ្ញានៅត្រង់ចំនុចខ្លះគឺមានលក្ខណៈថ្មីច្រើន ។ ដូចនេះខ្លួនត្រូវការពេលវេលាខ្លះដើម្បីពិភាក្សាជាមួយកូនក្តីរបស់ខ្លួនដើម្បីឆ្លើយតប ។ ភ្លាមៗអង្គជំនុំជម្រះសាលាដំបូងបានរំឭកថាសហមេធាវីការពារឲ្យជនជាប់ចោទម្នាក់ៗមានពេលកន្លះថ្ងៃក្នុងការឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានចោទប្រកាន់របស់សហព្រះរាជអាជ្ញា ។ ប្រសិនបើក្នុងករណីជនជាប់ចោទណាម្នាក់មានបំណងឡើងធ្វើសេចក្តីឆ្លើយតប ពេលវេលារបស់ជនជាប់ចោទនឹងត្រូវគិតបញ្ចូលនៅក្នុងរយៈពេលដែលផ្តល់ឲ្យកន្លះថ្ងៃនោះ ។ សហមេធាវីអន្តរជាតិរូបនេះនៅតែទទូចសុំការអនុញ្ញាតឲ្យខ្លួនបានធ្វើសេចក្តីសន្និដ្ឋានតបនៅថ្ងៃស្អែក ដោយយោងទៅលើរបៀបវារៈនៃសវនាការដែលបានកំណត់ដោយអង្គជំនុំជម្រះផ្ទាល់នៅក្នុងគេហទំព័រនៃសាលាក្តីមួយនេះ ។ ប៉ុន្តែសំណើនេះមិនទទួលបានការឆ្លើយតបពីលោក ប្រធានអង្គជំនុំជម្រះ និល ណុន ឡើយ ។

បន្ទាប់ពីបញ្ចប់សេចក្តីថ្លែងការណ៍របស់ជនជាប់ចោទ នួន ជា សហមេធាវីអន្តរជាតិលោក ម៉ៃឃើល ផេស្តមែន នៅតែព្យាយាមស្នើសុំការអនុញ្ញាតពីអង្គជំនុំជម្រះម្តងទៀតអំពីការឆ្លើយតបរបស់ខ្លួនទៅនឹងការចោទប្រកាន់របស់សហព្រះរាជអាជ្ញា ។ ប៉ុន្តែសំណើនេះនៅតែមិនត្រូវបានអង្គជំនុំជម្រះអនុញ្ញាតដដែល ។ ផ្ទុយទៅវិញត្រូវបានអង្គជំនុំជម្រះបដិសេធដោយហេតុថា មេធាវីមិនអាចធ្វើសេចក្តីសន្និដ្ឋានតបបានទៀតឡើយ ព្រោះជនជាប់ចោទ នួន ជា បានប្រើពេលវេលាដែលអង្គជំនុំជម្រះបានផ្តល់ឲ្យស្ទើរទាំងអស់ ។ ម្យ៉ាងទៀត អង្គជំនុំជម្រះយល់ឃើញថាសេចក្តីថ្លែងការណ៍របស់ជនជាប់ចោទ នួន ជា គឺសមល្មមចំពោះការឆ្លើយតបទៅនឹងការចោទប្រកាន់សហព្រះរាជអាជ្ញា ។

បញ្ហាគួរឲ្យសម្គាល់មួយទៀតនៅពេលនោះគឺ សហមេធាវីការពារក្តីឲ្យជនជាប់ចោទ នួន ជា គឺ លោក ម៉ៃឃើល ផេស្តមែន បានស្នើសុំទៅអង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីមានឱកាសបានឡើងធ្វើកំណត់សម្គាល់ពាក់ព័ន្ធនឹងការចោទប្រកាន់លើជនជាប់ចោទនៅក្នុងសវនាការ ។ ចំពោះការស្នើសុំនេះអាចនិយាយបានថា វាជាលើកទីមួយហើយដែលសហមេធាវីការពារក្តីឲ្យជនជាប់ចោទ នួន ជា គាំទ្រការស្នើសុំរបស់សហមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី ។ ទោះជាយ៉ាងណាសំណើនេះនៅតែត្រូវបានអង្គជំនុំជម្រះសាលាដំបូងច្រានចោលដដែល ។


មេធាវីអន្តរជាតិ ម៉ៃឃើល ផេស្តមែន (រូបថត : មជ្ឈមណ្ឌលឯកសារកម្ពុជា)

កំណត់សម្គាល់មួយទៀត ដែលមាននៅអំឡុងពេលនៃការធ្វើសេចក្តីថ្លែងការណ៍របស់ជនជាប់ ចោទ នួន ជា នៅក្នុងសវនាការមានអ្នកចូលរួមទស្សនាម្នាក់បានបញ្ចេញសូរសំឡេងមិនពេញចិត្តទៅនឹងការលើកឡើងរបស់ជនជាប់ចោទ នួន ជា នៅពេលដែលជនជាប់ចោទរូបនេះបានលើកឡើងអំពីភាពអយុត្តិធម៌របស់អង្គជំនុំជម្រះមកលើខ្លួន ។

### ◆ សវនាការថ្ងៃទី៣

មានបញ្ហាមួយទៀតកើតឡើងក្រោយពេលមានសំណើសុំពីសហព្រះរាជអាជ្ញា និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅថ្ងៃទី៣ដែលជាថ្ងៃចុងបញ្ចប់នៃសវនាការ ។ ព្រះរាជអាជ្ញា ជា លាង ស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងបញ្ជាក់ឲ្យបានច្បាស់លាស់ពីការចូលរួមរបស់ជនជាប់ចោទ អៀង សារី ដោយហេតុថាជនជាប់ចោទធ្លាប់បានសម្រេចថាខ្លួនមិនធ្វើសក្ខីកម្មនៅពេលសវនាការ តែក្រោយពេលធ្វើសេចក្តីថ្លែងការណ៍ពាក់ព័ន្ធនឹងការលើកលែងទោសនិងអនុគ្រោះទោស ជនជាប់ចោទ អៀង សារី និយាយថាខ្លួននឹងចូលរួមសវនាការក្នុងករណីចាំបាច់ ។ ចំណែកមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើឲ្យជនជាប់ចោទ អៀង សារី ឆ្លើយតបសង្ខេបៗទៅនឹងសំណួររបស់ភាគីដើម្បីជាប្រយោជន៍ដល់ការយល់ដឹងរបស់ជនរងគ្រោះ និងសាធារណជនទូទៅ ។ សំណើសុំទាំងពីរនេះត្រូវបានមេធាវីការពារក្តីឲ្យ អៀង សារី មានប្រតិកម្មយ៉ាងខ្លាំង ។ មេធាវីខាណារ៉ាស បានលើកឡើងថា សហព្រះរាជអាជ្ញាគប្បីយល់ឲ្យបានច្បាស់ទៅលើពាក្យ «ធ្វើសក្ខីកម្ម» និង «ការចូលរួមរបស់ជនជាប់ចោទ» ។ ជនជាប់ចោទ អៀង សារី អាចចូលរួមគ្រប់ដំណាក់កាលនៃសវនាការ ហើយការចូលរួមនេះជនជាប់ចោទអាចធ្វើការណែនាំមេធាវីរបស់ខ្លួនបានតែជនជាប់ ចោទ អៀង សារី នឹងមិនធ្វើសក្ខីកម្មអ្វីទាំងអស់នៅពេលសវនាការ ។ ឆ្លើយតបទៅនឹងសំណូមពររបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី មេធាវីខាណារ៉ាស បានលើកឡើងថា ការនៅស្ងៀមមិនឆ្លើយតបទៅនឹងសំណួររបស់ចៅក្រម ឬភាគីគឺជាសិទ្ធិរបស់ជនជាប់ចោទ ហើយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី គប្បីយល់ឲ្យបានច្បាស់ពីសិទ្ធិនៅស្ងៀមមិនឆ្លើយតបនេះ ។

## ■សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង របស់ជនជាប់ចោទ អៀង ធីរិទ្ធ

កាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចេញសេចក្តីសម្រេចស្តីពីសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ ។ អង្គជំនុំជម្រះបានសម្រេចថា ជនជាប់ចោទ អៀង ធីរិទ្ធ មិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមដំណើរការសវនាការទេ ។ មូលដ្ឋានវាយតម្លៃពីសម្បទាក្នុងការចូលរួមសវនាការរបស់ជនជាប់ចោទ អៀង ធីរិទ្ធ អង្គជំនុំជម្រះបានធ្វើការពិចារណាទៅលើលក្ខខណ្ឌដែលបានកំណត់ពីសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការដូចបានកំណត់នៅក្នុងរឿងក្តីស្រ្តូហ្កា របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ។ អង្គជំនុំជម្រះបានកំណត់ថា ជនជាប់ចោទត្រូវមានសមត្ថភាពធ្វើសក្ខីកម្មការពារខ្លួន ជជែកតតាំងក្នុងសវនាការ យល់ដឹងពីបទចោទ យល់ដឹងលម្អិតពីភ័ស្តុតាង យល់ដឹងពីកិច្ចដំណើរការនីតិវិធី និងអាចធ្វើការណែនាំមេធាវីរបស់ខ្លួនបាន ។ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងយល់ស្របជាមួយអ្នកជំនាញដែលថាជនជាប់ចោទ អៀង ធីរិទ្ធ មានការបាត់បង់ការចងចាំរយៈពេលវែង និងរយៈពេលខ្លី ដែលបណ្តាលឲ្យជនជាប់ចោទរូបនេះនឹងមិនអាចយល់បានពេញលេញនូវកិច្ចដំណើរការនីតិវិធីរបស់តុលាការដើម្បីអាចឲ្យខ្លួនណែនាំមេធាវី និងអាចជជែកតតាំងការពារខ្លួននៅក្នុងសវនាការប្រកបដោយប្រសិទ្ធិភាពបាន ។


អៀង ធីរិទ្ធ ក្នុងបន្ទប់សវនាការ (រូបថត ៖ អ.វ.ត.ក)

អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានបើកសវនាការពីរលើករួចមកហើយ ដើម្បីអនុញ្ញាតឲ្យភាគីទាំងអស់នៅក្នុងសវនាការសួរដេញដោលទៅលើអ្នកជំនាញដែលចាត់តាំងដោយអង្គជំនុំជម្រះឲ្យធ្វើការវាយតម្លៃទៅលើសម្បទាក់ងការចូលរួមសវនាការរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ។

នៅក្នុងសវនាការលើកទីមួយ អង្គជំនុំជម្រះសាលាដំបូងបានបើកនៅថ្ងៃទី២៩ដល់ទី៣១ ខែសីហា ឆ្នាំ២០១១ ដោយមានការសួរដេញដោលទៅលើរបាយការណ៍របស់អ្នកជំនាញព្យាបាលមនុស្សចាស់ លោកសាស្រ្តាចារ្យ ចន ខាំប៉ែល ស្តីពីសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ និង នួន ជា ។ លោកសាស្រ្តាចារ្យ ចន ខាំប៉ែល បានធ្វើការកត់សម្គាល់ថា ជនជាប់ចោទ អៀង ធីរិទ្ធ មានជំងឺចុះខ្សោយផ្នែកបញ្ញា ដែលអាចបណ្តាលឲ្យមានការបាត់បង់ការចងចាំ ឬមានការចុះខ្សោយផ្នែកស្មារតី ។ លោកសាស្រ្តាចារ្យ ចន ខាំប៉ែល បានសន្និដ្ឋានថា ជនជាប់ចោទ អៀង ធីរិទ្ធ មានការលំបាកក្នុងការយល់ពីចរិតលក្ខណៈនៃបទចោទប្រកាន់មកលើខ្លួន ការតាមដាននីតិវិធីរបស់តុលាការ ការធ្វើសក្ខីកម្មដើម្បីការពារខ្លួន ការណែនាំមេធាវីការពារក្តី និងការយល់ពីសក្ខីកម្មរបស់សាក្សីដែលចោទប្រកាន់មកលើខ្លួន ។ យោងទៅលើការសន្និដ្ឋាននេះ លោកសាស្រ្តាចារ្យ ចន ខាំប៉ែល បានផ្តល់អនុសាសន៍ដល់អង្គជំនុំជម្រះសាលាដំបូងឲ្យធ្វើការចាត់តាំងអ្នកជំនាញបន្ថែមដើម្បីវាយតម្លៃលើសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការ ចូលរួមសវនាការ ។

លើកទីពីរ អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការនៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០១១ ស្តីពីសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ ដើម្បីឲ្យភាគីសួរដេញដោលទៅលើរបាយការណ៍របស់អ្នកជំនាញថ្មីចំនួន៤រូប ដែលអង្គជំនុំជម្រះបានចាត់តាំងតាមសំណើរបស់សាស្រ្តាចារ្យ ចន ខាំប៉ែល ។ អ្នកជំនាញដែលមានវត្តមាននៅក្នុងសវនាការលើកទីពីរនេះមាន វេជ្ជបណ្ឌិត ស៊ីណា

ហ៊ាហែរុល និង វេជ្ជបណ្ឌិត ហួត លីណា ។ អ្នកជំនាញទាំងពីរបាន បញ្ជាក់ថា ជនជាប់ចោទ អៀង ធីរិទ្ធមានជំងឺវង្វេងវង្វាន់ស្មារតីធ្ងន់ធ្ងរកម្រិតមធ្យម ហើយជនជាប់ចោទមានការលំបាកក្នុងការតាមដាននីតិវិធីរបស់តុលាការ ។

បន្ទាប់ពីមានការវាយតម្លៃ និងសន្និដ្ឋានទាំងពីរលើករបស់អ្នកជំនាញ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ជនជាប់ចោទ អៀង ធីរិទ្ធ មិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមដំណើរការសវនាការ និងបានបញ្ជាឲ្យធ្វើការបំបែកកិច្ចដំណើរការនីតិវិធីដែលចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ អៀង ធីរិទ្ធ ចេញពីសំណុំរឿង០០២ ដោយយោងទៅលើវិធាន៨៩ស្ទួនពីរ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី ។ អង្គជំនុំជម្រះបានប្រកាសថានីតិវិធីចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ អៀង ធីរិទ្ធ នឹងត្រូវផ្អាក ។ ដោយមិនអាចឈានទៅដល់សេចក្តីសម្រេចជាឯកច្ឆ័ន្ទ ថាតើអង្គជំនុំជម្រះអាចបន្តឃុំខ្លួន និងព្យាបាលជនជាប់ចោទ អៀង ធីរិទ្ធ នៅក្នុងមន្ទីរពេទ្យ ឬនឹងដោះលែងជនជាប់ចោទរូបនេះដោយគ្មានលក្ខខណ្ឌ អង្គជំនុំជម្រះបានបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ពីការឃុំឃាំងនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ


អ្នកចូលរួមសវនាការ (រូបថត ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

កម្ពុជា ។

មួយថ្ងៃបន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ឲ្យនៅក្រោមន្ទីរឃុំឃាំងដោយមិនមានលក្ខខណ្ឌ សហព្រះរាជអាជ្ញាបានដាក់ពាក្យបណ្តឹងប្តឹងទៅអង្គជំនុំជម្រះតុលាការកំពូលប្រឆាំងនឹងការសម្រេចដោះលែងនេះនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១១ ។ យោងទៅលើវិធាន៨២(៦) នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាត្រូវបានតម្រូវឲ្យដាក់សំណើសុំផ្អាកសេចក្តីសម្រេចដោះលែងទៅអង្គជំនុំជម្រះតុលាការកំពូលក្នុងអំឡុងពេល២៤ម៉ោង ។ នៅក្នុងបណ្តឹងឧទ្ធរណ៍នោះ សហព្រះរាជអាជ្ញាលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានសម្រេចដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយផ្អែកទៅលើមូលដ្ឋានអង្គហេតុ និងអង្គច្បាប់ដែលមានកំហុស និងបានអនុវត្តន៍នូវឆន្ទានុសិទ្ធិរបស់ខ្លួនដោយមិនសមស្រប ។ សហព្រះរាជអាជ្ញាបានស្នើសុំទៅអង្គជំនុំជម្រះតុលាការកំពូលធ្វើមោឃភាពទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឲ្យដោះលែងជនជាប់ ចោទ អៀង ធីរិទ្ធ ដោយគ្មានលក្ខខណ្ឌ និងស្នើសុំឲ្យកែប្រែទៅលើសេចក្តីសម្រេចនោះ ដោយបន្តដាក់ជនជាប់ចោទឲ្យនៅស្ថិតនៅក្នុងមន្ទីរឃុំឃាំងដើម្បីទទួលការពិនិត្យរោគវិនិច្ឆ័យ ឬការព្យាបាលផ្សេងៗ និងធ្វើការពិនិត្យសារជាថ្មីនៅរៀងរាល់៦ខែម្តង ដូចជាការណែនាំរបស់អ្នកជំនាញដែលធ្លាប់បានធ្វើឡើងនៅក្នុងសវនាការ ។

បណ្តឹងឧទ្ធរណ៍ដែលប្តឹងទៅអង្គជំនុំជម្រះតុលាការកំពូលរបស់សហព្រះរាជអាជ្ញានឹងរារាំងដល់ការដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ចេញពីមន្ទីរឃុំឃាំងជាបណ្តោះអាសន្ន រហូតដល់មានការសម្រេចពីអង្គជំនុំជម្រះតុលាការកំពូល ។ ទោះបីជា អៀង ធីរិទ្ធ កំពុងតែបន្តស្ថិតនៅក្នុងមន្ទីរឃុំឃាំងយ៉ាងណាក្តី ក៏នៅក្នុងសវនាការលើអង្គសេចក្តីនៅថ្ងៃទី២១ ខែវិច្ឆកា ឆ្នាំ២០១១ មិនបានមានវត្តមានរបស់ជនជាប់ចោទ អៀង ធីរិទ្ធ នៅក្នុងបន្ទប់សវនាការឡើយ ។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលស្តីពីបណ្តឹងឧទ្ធរណ៍នេះនឹងត្រូវចេញនៅក្នុងរយៈពេល ១៥ ថ្ងៃនៅក្រោយពេលដែលក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូលទទួលបានសំណុំរឿងពីភាគី ។

## ■ បណ្តឹងដិតចិត្តប្រឆាំងទៅនឹងចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង

*នៅសវនាការថ្ងៃទី១ បន្ទាប់ពីប្រធានអង្គជំនុំជម្រះសាលាដំបូងប្រកាសបើកសវនាការលើអង្គសេចក្តី មេធាវីរបស់ជនជាប់ចោទ នួន ជា និងមេធាវីរបស់ជនជាប់ចោទ អៀង សារី បានធ្វើសំណើបន្តបន្ទាប់គ្នា សុំដក (បណ្តឹងដិតចិត្ត) ចៅក្រម ស៊ីលវៀ ខាតវ្រ៉ាយត៍ (Silvia Cartwright) ចេញពីសមាសភាពអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង០០២ ។ បន្ថែមលើសំណើសុំដកចៅក្រមដោយផ្ទាល់មាត់នៅពេលសវនាការ មេធាវីទាំងពីរក្រុមបានដាក់សារណាជាលាយលក្ខអក្សរដោយបញ្ជាក់ពីមូលហេតុនៃបណ្តឹងដិតចិត្តនេះ ។[១] បណ្តឹងដិតចិត្តរបស់មេធាវីទាំងពីរក្រុមធ្វើឡើងក្រោយពីទទួលបានដំណឹងថា មានការជួបប្រជុំជាសម្ងាត់រវាងចៅក្រម ខាតវ្រ៉ាយត៍ ព្រះរាជអាជ្ញាអន្តរជាតិ អេនឌ្រូ ខេលី និងលោក Knut Rosandhaug ជាអនុប្រធានការិយាល័យរដ្ឋបាលរបស់តុលាការ ។[២]*

*នៅក្នុងសារណាបណ្តឹងដិតចិត្ត មេធាវីជនជាប់ចោទ នួន ជា បានស្នើសុំអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យចៅក្រម ខាតវ្រ៉ាយត៍ លាលែងពីតំណែងមួយរយៈ ដោយរង់ចាំសេចក្តីសម្រេចលើបណ្តឹងដិតចិត្តនេះសិន ឬឲ្យលាលែងរហូតពីសមាសភាពចៅក្រមនៅក្នុងនីតិវិធីជំនុំជម្រះលើសំណុំរឿង០០២ទាំងមូលតែម្តង ។[៣] ចំណែកសារណាមេធាវីរបស់ អៀង សារី បានស្នើសុំបីចំណុចគឺ ទី១) សុំឲ្យចៅក្រម ខាតវ្រ៉ាយត៍ លាលែងពីតំណែងដោយខ្លួនឯងរហូតដល់មានការសម្រេចលើបណ្តឹងដិតចិត្តរបស់ខ្លួន ទី២) សុំឲ្យមានការស៊ើបអង្កេតលើបញ្ហាដែលពាក់ព័ន្ធនឹងសំណុំរឿង០០២ ទាំងអស់ដែលចៅក្រម ខាតវ្រ៉ាយត៍ ព្រះរាជអាជ្ញាអន្តរជាតិ អេនឌ្រូ ខេលី និងអ្នកផ្សេងៗទៀតបានលើកយកមកពិភាក្សានៅពេលប្រជុំដោយសម្ងាត់ និង ទី៣) សុំអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យចៅក្រម ខាតវ្រ៉ាយត៍ និងព្រះរាជអាជ្ញាអន្តរជាតិ អេនឌ្រូ ខេលី ធ្វើសេចក្តីថ្លែងការណ៍លាតត្រដាងលើបញ្ហាដែលអ្នកទាំងពីរបានពិភាក្សាក្នុងពេលប្រជុំសម្ងាត់នោះ ។[៤]*

*មេធាវីជនជាប់ចោទ នួន ជា បានសន្និដ្ឋានថា កិច្ចប្រជុំរវាងចៅក្រម ខាតវ្រ៉ាយត៍ ព្រះរាជអាជ្ញាអន្តរជាតិ អេនឌ្រូ ខេលី និងលោក Rosandhaug មិនត្រឹមតែផ្តោតតែទៅលើបញ្ហារដ្ឋបាល និងការរៀបចំប៉ុណ្ណោះទេ គឺថែមទាំងពិភាក្សាលើបញ្ហាសំខាន់ៗមួយចំនួនទៀត ។ បញ្ហាទាំងនោះរួមមានៈ ការបន្តជ្រៀតជ្រែកពីសំណាក់រាជរដ្ឋាភិបាលកម្ពុជាមកលើតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ឥទ្ធិពលនៃការជ្រៀតជ្រែកនេះទៅលើសំណុំរឿង០០២ ០០៣ និង០០៤ និងសំណើរបស់មេធាវីការពារក្តីសុំឲ្យមានការស៊ើបអង្កេតដោយឯករាជ្យទៅលើការជ្រៀតជ្រែកនេះ ។[៥]*

*មូលហេតុចម្បងដែលនាំឲ្យមានបណ្តឹងដិតចិត្តនាពេលនេះ គឺដោយសារមេធាវីការពារក្តីទាំងពីរក្រុមព្រួយបារម្ភពីភាពមិនលម្អៀងរបស់លោកស្រីចៅក្រម ខាតវ្រ៉ាយត៍ នៅក្នុងការជំនុំជម្រះនៅក្នុងសំណុំរឿងកូនក្តីរបស់ខ្លួន ។ ជាក់ស្តែងមេធាវីជនជាប់ចោទ នួន ជា បានលើកឡើងថា“ការចូលរួមរបស់ ចៅក្រម ខាតវ្រ៉ាយត៍ ក្នុងកិច្ចប្រជុំរវាងភាគីតែម្ខាង កិច្ចប្រជុំដែលហួសដែនអំណាច និងកិច្ចប្រជុំមិនផ្លូវការជាមួយលោក អេនឌ្រូ ខេលី និង/ឬ លោក*

---

*[១] បណ្តឹងដិតចិត្តជាបន្ទាន់ចំពោះចៅក្រម ខាតវ្រ៉ាយត៍ ចុះថ្ងៃទី២១ ខែវិច្ឆិកាឆ្នាំ ២០១១ ឯកសារលេខ E137/2 (បណ្តឹងដិតចិត្តរបស់ នួន ជា) ។ សូមមើលផងដែរសំណើសុំរបស់ អៀង សារី ឲ្យស៊ើបអង្កេតទាក់ទងទៅនឹងការប្រជុំសម្ងាត់រវាងព្រះរាជអាជ្ញាអន្តរជាតិ អេនឌ្រូ ខេលី ចៅក្រមអន្តរជាតិ ខាតវ្រ៉ាយត៍ និងអ្នកផ្សេងៗទៀត ចុះថ្ងៃទី១៨ ខែវិច្ឆិកាឆ្នាំ ២០១១ ឯកសារលេខ E137/2.1 (សំណើសុំរបស់ អៀង សារី) ។*

*[២] សំណើសុំរបស់ អៀង សារី កថាខណ្ឌទី៤ ។*

*[៣] បណ្តឹងដិតចិត្តរបស់ នួន ជា កថាខណ្ឌទី២០ ។*

*[៤] សំណើសុំរបស់ អៀង សារី កថាខណ្ឌចុងក្រោយនៃសេចក្តីសន្និដ្ឋាន ។*

*[៥] បណ្តឹងដិតចិត្តរបស់ នួន ជា កថាខណ្ឌទី១៧ ។*

Rosandhaug (ហើយការខកខានរបស់គាត់ក្នុងការផ្តល់ព័ត៌មានអំពីកិច្ចប្រជុំនេះ) បាននាំឲ្យមានការលេចចេញនូវភាពលម្អៀងដែលមិនអាចទទួលយកបាន» ។[៦] មេធាវីទាំងពីរក្រុមបានលើកយកមូលដ្ឋានច្បាប់ដែលបានចែងក្នុងមាត្រា៩នៃក្រមសីលធម៌ចៅក្រមរបស់កម្ពុជាយកមកសំអាងដើម្បីគាំទ្រនូវបណ្តឹងជំទាស់... ចិត្តរបស់ខ្លួន ។ មាត្រានេះចែងថា «...ចៅក្រមមិនត្រូវប្រាស្រ័យទាក់ទងជាមួយភាគីណាមួយក្នុងអំឡុងពេលនីតិវិធីរឿងក្តីកំពុងតែដំណើរការ ដោយអវត្តមានភាគីម្ខាងទៀតឡើយ លើកលែងតែមានច្បាប់អនុញ្ញាត ឬមានការយល់ព្រមពីភាគីដែលអវត្តមាននោះ» ។[៧] ដូចនេះការណ៍ដែលចៅក្រម ខាតព្រ៊ាយត៍ ជួបប្រជុំជាមួយព្រះរាជអាជ្ញាអន្តរជាតិ អេនឌ្រូ ខេលី ដោយសម្ងាត់គឺជាការរំលោភលើក្រមសីលធម៌របស់ចៅក្រម ។[៨]


អ្នកចូលរួមសវនាការ (រូបថត : មជ្ឈមណ្ឌលឯកសារកម្ពុជា)

មេធាវីការពារក្តីទាំងពីរក្រុមបានដាក់សារណានៃបណ្តឹងជំទាស់... ចិត្តមុនពេលសវនាការថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១ ព្រមទាំងបានធ្វើសំណើដោយផ្ទាល់មាត់នៅពេលសវនាការលើអង្គសេចក្តីឲ្យដកចៅក្រម ស៊ីលវៀ ខាតព្រ៊ាយត៍ ចេញពីដំណើរការនីតិវិធីជំនុំជម្រះក្នុងសំណុំរឿង០០២ តែសំណើនេះមិនទាន់ត្រូវបានអង្គជំនុំជម្រះយកមកដោះស្រាយនូវឡើយ ។ នៅក្នុងរយៈពេលសវនាការលើអង្គសេចក្តីដែលបានប្រព្រឹត្តឡើងចាប់ពីថ្ងៃទី២១-២៣ ខែវិច្ឆិកា ឆ្នាំ២០១១ គឺមិនមានការជជែកដេញដោល ឬមានសេចក្តីសម្រេចណាមួយពាក់ព័ន្ធទៅនឹងបណ្តឹងជំទាស់... ចិត្តនេះឡើយ ។ ដូចនេះសំណួរចោទសួរឡើងថា តើកិច្ចដំណើរការនីតិវិធីលើអង្គសេចក្តីក្នុងសំណុំរឿង០០២ដំណើរការយ៉ាងដូចម្តេចនៅខណៈដែលសមាសភាពចៅក្រមមួយរូបដែលនឹងត្រូវជំនុំជម្រះនៅក្នុងសំណុំរឿងនេះកំពុងត្រូវបានមេធាវីការពារក្តីធ្វើបណ្តឹងជំទាស់... ចិត្ត?

វិធាន៣៨ កថាខណ្ឌទី៥ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចែងថាៈ «...ចៅក្រមដែលកំពុងមានបញ្ហាអាចបន្តចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី ដោយរង់ចាំសេចក្តីសម្រេចស្តីពីបណ្តឹងជំទាស់... ចិត្ត...» ។[៩] យោងតាមវិធាននេះចៅក្រមដែលកំពុងត្រូវបានភាគីប្តឹងជំទាស់... ចិត្ត អាចចូលរួមនៅក្នុងកិច្ចដំណើរការជំនុំជម្រះបានជាធម្មតា ដរាបណាមិនទាន់មានសេចក្តីសម្រេចដកចៅក្រមនោះចេញពីកិច្ចដំណើរការនីតិវិធីជំនុំជម្រះលើសំណុំរឿង ។ បន្ថែមលើនេះ លទ្ធផលដែលបានបំពេញដោយចៅក្រមរូបនេះមុនពេលមានសេចក្តីសម្រេចលើពាក្យបណ្តឹងជំទាស់... ចិត្តគឺមានសុពលភាពអាចទទួលយកបាន ។[១០]

**ពិនិត្យ និងផ្ទៀងផ្ទាត់ដោយ ម៉ាន់ថាន់ ពៅដារ៉ា**

---

[៦] បណ្តឹងជំទាស់... ចិត្តរបស់ នួន ជា កថាខណ្ឌទី១៥ ។

[៧] សំណើសុំរបស់ អៀង សារី កថាខណ្ឌទី១៣ ។ សូមមើលផងដែរនៅបណ្តឹងជំទាស់... ចិត្តរបស់ នួន ជា កថាខណ្ឌទី១០ ។

[៨] សំណើសុំរបស់ អៀង សារី កថាខណ្ឌទី៣០ ។

[៩] វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (វិសោធនកម្មលើកទី៨) សូមមើល www.eccc.gov.kh ។

[១០] វិធាន៣៨ កថាខណ្ឌទី៩ នៃវិធានផ្ទៃក្នុង ។

មជ្ឈមណ្ឌលឯកសារកម្ពុជា

*ប្រអប់សំបុត្រលេខ១១១០, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា*

*ទូរស័ព្ទ: (៨៥៥) ២៣ ២១១ ៨៧៥*

*ទូរសារ: (៨៥៥) ២៣ ២១០ ៣៥៨*

*អ៊ីម៉ែល: dccam@online.com.kh*

*គេហទំព័រ: www.dccam.org ឬ www.cambodiatribunal.org*



*គម្រោងនេះទទួលជំនួយហិរញ្ញវត្ថុពីមូលនិធិ*

*John D. and Catherine T. MacArthur Foundation ។*




***ឌី សុជាតា***

***សុជាតា*** *ជានិស្សិតថ្នាក់បរិញ្ញាប័ត្រផ្នែកច្បាប់ សិក្សាជាភាសាអង់គ្លេសនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។*



***គីម ម៉ារីយ៉ាន***

***ម៉ារីយ៉ាន*** *បានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រផ្នែកច្បាប់ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ ម៉ារីយ៉ាន ជាអតីតជ័យលាភីថ្នាក់ជាតិនៅក្នុងការប្រកួតសវនាការប្រឌិត ឆ្នាំ២០១០ ។*



***លឹម ជ័យទត្ត***

***ជ័យទត្ត*** *ទទួលបានបរិញ្ញាប័ត្រច្បាប់ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ ជ័យទត្ត ជាអតីតជ័យលាភីថ្នាក់ជាតិនៅក្នុងការប្រកួតសវនាការប្រឌិត ឆ្នាំ២០១០ ។*



***ចាន ប្រាថ្នា***

***ប្រាថ្នា*** *ទទួលបានបរិញ្ញាប័ត្រច្បាប់ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ ប្រាថ្នា សព្វថ្ងៃកំពុងត្រៀមប្រឡងសិក្សាវិជ្ជាជីវៈមេធាវីនៅកម្ពុជា ។*



អៀង សារី ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ប្រភព ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មជ្ឈមណ្ឌលឯកសារកម្ពុជា រក្សាសិទ្ធិ ខែធ្នូ ឆ្នាំ២០១១